## វគ្គទី៤

## ម្ចាស់ផ្កា Saffron

ស្នូរទះដៃរំជួយវេទិកាសម្រស់បុប្ផាអាស៊ី ដែលមានវត្តមានបុស្សាចម្រុះជាតិសាសន៍រាប់សិបទងមករេរាំលំអលើកម្រាលព្រំក្រហមនៃឆ្នេរសូម៉ាត្រា បង្កើនអោយកោះបាលីនូវទិដ្ឋភាពដ៏រំភើបរីករាយសម្រាប់ជាតិកន្លង់ទាំងឡាយ។

នៅក្រោមស្រមោលចុងក្រោយនៃអំណាចទិនករពណ៌មាសជាសញ្ញាថារាត្រីកាលហៀបនឹងឈានចូលមកដល់ រូបរាងកិន្នរីខ្ពស់ស្រាវមកពីប្រទេសកម្ពុជាដែលពត់ពែនស្វាហាប់លើឆាកដែនសមុទ្រ បានទាក់ទាញអោយអភិជននានាដែលជាភ្ញៀវកិត្តិយសលង់ទៅក្នុងតម្រេកដោយភាពប្រណិតស្រទន់នៃរូបសម្រស់នារីខ្មែរ។

មយូរាទាំង៧ដួងនៃកិន្នរីFashion បានបញ្ឈប់ចលនាពីក្រោមស្នូរទះដៃកក្រើកពីលើភាពរេរាំនៃរលកឆ្នេរសូម៉ាត្រាទន្ទឹមនឹងពេលដែលសំឡេងអ្នកគ្រប់គ្រងកម្មវិធីលាន់មករំពងក្រអួនះ

សូមអបអរសាទរកញ្ញា កេតឌីម៉ា ដែលជាអ្នកដឹកនាំក្រុមកិន្នរីFashion មកពីប្រទេសកម្ពុជា!

រាមនរិន្ទចោលក្រសែភ្នែកទៅរកនារីរាងរាវខ្ពស់ដែលនាំកាយល្វតល្វៃមកបង្ហាញនៅចុងខាងមុខបង្អស់នៃឆាកក្រោមសូរសម្លេងសាទរទ្រហឹងអឹងអាប់។

សម្រស់បបូរមាត់ដែលញញឹមនឹងនអមជាមួយពន្លឺភ្នែកស្លូតបូត អមលំអដោយសរសៃសក់ទន់ រលោងហើរប្រលែងបត់បែនតាមកម្លាំងវាយោសមុទ្រដាស់កាមានរះអោយរំលឹកដល់រាត្រីកាលមួយដែលអ្នកបានចំណាយពេលវេលានៅជាមួយនាងតែពីរនាក់។

នាងស្អាតយ៉ាងនេះ ម៉េចក៏ច្រើនខែមកហើយយើងភ្លេចពីនាងទៅកើតកេតឌីម៉ា?

(បុរសសម្បុរស្រអែមលួចគិតតែម្នាក់ឯង)

គេដៀងភ្នែកមករកទិសមួយផ្សេងនៅចំហៀងខាងស្តាំ ជាទីដែលប្រាកដថាសិទ្ធិគុណ និងក្រុមរបស់គេកំពុងមានវត្តមាននោះក៏ឃើញនាយសិទ្ធិគុណសម្លឹងទៅលើឆាកដោយស្លុងស្មារតី។ ពន្លឺភ្នែកដែលមិនពិបាកសម្រាប់បុរសដូចគ្នាក្នុងការវាយតម្លៃនោះ បានធ្វើអាយរាមនរិន្ទ

ប្រាកដចិត្តរួចហើយថាសិទ្ធិគុណនឹងចុកឈាមបើដឹងថាកេតឌីម៉ានឹងត្រូវជួបអ្នកនៅ Amandariក្នុងរាត្រីនេះ។

គេដកភ្នែកមកវិញដោយមិនភ្លេចចោលស្នាមញញឹមលើបបូរមាត់។មនុស្សជំនិតឈ្មោះរឿនអោនមកខ្សឹបក្បែរត្រចៀក៖

កម្មវិធីខ្មែរចប់ហើយទាន!

រាមនរិន្ទលើកនាឡិកាមើល ហើយនិយាយតប៖

បន្តិចទៀត យើងត្រឡប់ទៅវិញ!

នៅពេលដែលគេងើបមុខសម្លឹងទៅរកឆាកបុប្ផាអាស៊ីជាលើកទី២ គេបានជំពាក់ភ្នែកនឹងធីតាម្ចាស់ក្រុមកិន្នរីដែលសម្លឹងមកផង។ ពន្លឺភ្នែកលាយឡំទៅដោយភាពព្រួយបារម្ភនោះ បានទាក់បុរសមកពីគ្រួសារអ្នកនយោបាយអោយផ្តោតសម្លឹងនាងតបវិញដកចេញលែងរួច។ ដូចសព្វមួយដងគេតែងស្វាគមន៍រកនាងនូវស្នាមញញឹមស្រស់សង្ហាក្នុងភាពជាបុរសរហូតដល់នាងត្រូវប្រញាប់ប្រញាល់ដក ភ្នែកចេញវិញហើយបន្តការងារលើឆាកក្នុងសភាពខ្វល់ខ្វាយ។

កេតឌីម៉ានាងពិបាកចិត្តព្រោះរឿងណាត់ទៅ Amandariមែនទេ? (រាមនរិន្ទគិតស្ងាត់ៗម្នាក់ឯង)

ហាក់យល់ចិត្តថៅហ្វាយនាយBirdដែលនៅក្បែរនោះអោនមកខ្សឹបខ្សៀវ៖

ខាងAmandariបានរៀបចំរួចរាល់ហើយទាន!

តាមពិតស្រស់ស្រីកេតឌីម៉ាមិនដឹងទាល់តែសោះ ថាប្រាក់ដែលនាងបានមកសង្គ្រោះជីវិតប្អូនពីជំងឺនោះ គឺត្រូវប្តូរនូវកិត្តិយស និងសេរីភាពរបស់ខ្លួនក្នុងកណ្តាប់ដៃប្រុសម្នាក់នេះលើសពីរាត្រីមួយនោះទៀតសោះ ហើយបើល្បែងឆ្កិនភ្នែករបស់អ្នកស្រីកុលាបត្រូវបាននាងរកឃើញទាន់មុននេះ អ្វីៗក៏ប្រហែលជាមិនអាក្រក់ដូចពេលនេះដែរ។

នៅពីក្រោយឆាកពីក្រោមបរិយាកាសរីករាយរបស់ក្រុមនារីខ្មែរ ដែលមានមោទនភាពនឹងជោគជ័យលើឆាកអន្តរជាតិអម្បាញ់មិញ កេតឌីម៉ារក្សាកិរិយានៅស្ងប់ស្ងាត់ឆ្ងាយពីគេ។

នាងដោះអលង្ការភណ្ឌ និងជូតសំអាតផ្ទៃមុខពីក្រោមការឃ្លាំមើលរបស់លំអងជាមិត្ត។

ចំពេលដែលកូនក្រុមជាច្រើនរបស់នាង ហាក់ចង់ចូលមករកនាងដើម្បីសំណេះសំណាល លេងសើចពីជ័យជំនះរបស់ពួកគេ លំអងបានអោយសញ្ញាថា នេះមិនមែនជាពេលវេលាសមរម្យឡើយព្រោះកេតឌីម៉ាកំពុងមានកង្វល់។ ដូច្នេះនារីកិន្នរីទាំងឡាយបានបែកគ្នាទៅរកកន្លែងសម្រាកអស់ បន្សល់នៅតែនារីទាំងពីរក្នុងបន្ទប់ទឹក។

លំអងរង់ចាំទាល់តែឌីម៉ាចេញពីបន្ទប់ផ្លាស់សំលៀកបំពាក់ទើបចូលទៅជិតនិយាយទៅកាន់នាងតិចៗ៖

ជោគជ័យក្នុងការសម្រុះសម្រួលជួយមីងកុលាបណ៎ាពួកម៉ាក!

កេតឌីម៉ាមិនឆ្លើយនាងឱនប្រមូលសម្ភារៈដាក់ក្នុងកាបូបរួចរូតបិត។ ប៉ុន្តែនាងកំពុងគិតក្នុងចិត្តតែម្នាក់ឯង៖

មីងកុលាបជាអ្នកល្មោភប្រាក់របស់គេ គាត់គួរតែទទួលខុសត្រូវ! យើងមិនអាចប្រថុយទៅជួយគាត់ទាំងអត់ទំនង  នាំតែមានទុក្ខទោសដល់ខ្លួនទេ!

នាងនិយាយចេញមកតិចៗដាក់មិត្ត៖

លំអង! ឯងដឹងទេ? ឃើញគេនៅមុខឆាកអម្បាញ់មិញ ខ្ញុំភ័យស្ទើរផុតដង្ហើមទៅហើយ! កុំថាឡើយដល់នៅសុខៗឲ្យទៅជួបគេ! គ្នាសុំទោសបើគ្នាមិនអាចជួយអីមីងកុលាបបាន! គ្នាហត់ណាស់ សុំទៅមុនហើយ!

លំអងដកដង្ហើមធំចំពោះសកម្មភាពនេះ។

លំអងប្រហែលមិនបានដឹងទេថាអ្នកគ្រូកេតឌីម៉ាដែលមានបុរសផ្សេងក្នុងបេះដូងទៅហើយ នាងម៉េចនឹងមានកម្លាំងចិត្តក្នុងការរវីមរវាមជាមួយរាមនរិន្ទច្រើន ដើម្បីជួយសម្រាលទោសកំហុសរបស់មីងកុលាបដូចដែលលំអងចង់បាននោះ។

នាងតាមសម្លឹងដំណើរកេតឌីម៉ាដែលចាកចេញរ៉ុយទៅ ហាក់មិនចង់ឮពាក្យលួងលោមអង្វររបស់មិត្ត លំអងដឹងស្រេចហើយថាផែនការកំពុងរលាយ។

នាងលើកទូរស័ព្ទចល័ត បន្ទាប់មកនិយាយតិចៗស្ទើរមិនចង់ឮ៖

ឥឡូវវាប្តូរចិត្តហើយ វាមិនព្រមទៅទេបង!

គ្មាននរណាដឹងទេថា អ្នកដែលកំពុងនិយាយទូរស័ព្ទជាមួយលំអងជានរណានោះ។

សន្ធិយាលាគ្របដណ្ដប់លើដែនកោះទាំងមូល។ ដួងច័ន្ទប្រឹងរះប្រឹមៗកំដរធម្មជាតិដ៏រាបសានាហេមន្តរដូវ។ ពន្លឺភ្លឺខៀវស្រអាប់ដែលចាំងជះលើផ្ទៃពសុធាហាក់បីដូចជាតាក់តែងឲ្យបរិយាកាសពេលរាត្រីមានភាពស្រងេះស្រងោចរកស្មានមិនត្រូវ។

យប់មិនទាន់ជ្រៅ តែសន្សើមចាប់ផ្ដើមធ្លាក់ត្រជាក់ដល់ថ្លើមប្រមាត់ខុសពីបរិយាកាសនៅក្នុងប្រទេសកំណើតធ្វើអោយកេតឪម៉ាកាន់តែទទួលអារម្មណ៍ឯកា និងស្រណោះស្រណោករកស្មានមិនត្រូវសោះ។

ចេញពីការងូតសំអាតខ្លួនក្នុងបន្ទប់ទឹក នារីមេក្រុមបង្ហាញម៉ូតក្នុងសំលៀកបំពាក់រាត្រីទន់រលោង គ្របក្រាលពីក្រៅដោយអាវវែងហៀរដល់កែង។ នាងឈរទ្រើងក្បែរបង្អួចសម្លឹងត្រង់មកទិសដែលសម្គាល់ថាជាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា តែនៅឆ្ងាយសែនឆ្ងាយប្រៀបដូចជាចំណោទសាកល្បងចំពោះបេះដូងនារីម្នាក់ ដែលកំពុងនឹកគិតដល់ម្ចាស់ចិត្តនាងយ៉ាងប្ដូរផ្ដាច់រហូតដល់ភ្លេចគិតថា នាងកំពុងមានណាត់ជាមួយបុរសមានអំណាច។

"បងKenថ្មីណេះបងកំពុងធ្វើអ្វី? មានដឹងទេថា ឪម៉ានឹកបងជាទីបំផុត ហើយអូនក៏កំពុងតែស្មុគស្មាញជាទីបំផុត! ទោះបីស្អែកនេះអូននឹងអាចវិលទៅកម្ពុជាវិញក៏ដោយ តែអូនស្ទើរមិនអាចរង់ចាំបាននោះទេ"។

-នឹកអ្នកណា?

ពាក្យតែបីម៉ាត់តែល្មមអាចបង្ខំអោយមាណវីងាកភ្លែតមករកប្រភពនៃសូរសម្លេង។ បុរសខ្ពស់ស្រាវដែលមានវត្តមានពីក្រោយខ្លួននាងតាំងពីពេលណាមកក៏មិនដឹង បានបង្ហាញខ្លួនជាមួយស្នាមញញឹមស្រស់សង្ហា។ ឃើញភ្លាមនាងចាំបាច់ត្រូវទទួលស្វាគមន៍ដោយស្នាមញញឹមពីដួងចិត្តមិនអាចទប់ បានដោយអំណាចនៃភាពភ្ញាក់ផ្អើលលាយឡំជាមួយអារម្មណ៍រំភើប។

បងKen?

បុរសសប្បុរសនាំកាយចូលមករកស្រីស្រស់ជាមួយដំណើរធ្ងន់ៗក្នុងភាពមាំទាំ។ គេមិនទាន់វាចាថាយ៉ាងណាមកកាន់នារីម្ចាស់បន្ទប់នៅឡើយ ដោយគ្រាន់តែញញឹមបង្ហាញសេចក្ដី

ស្នេហានឹករលឹកតាមពន្លឺភ្នែក និងលូកដៃមកបម្រុងក្រសោបកាយធីតា ប៉ុន្តែត្រូវនាងគេចចេញតាមសភាវៈនារីអៀនប្រៀន។

ខ្លាចគេអន់ចិត្ត កេតឌីម៉ានិយាយបន្លប់៖

ក្រែងថាអត់នៅបាលីទេ? ម៉េចចាំកុហក?

ឃើញនាងដកខ្លួនមិនអោយនៃបនិត្យ Kenក៏មិនបង្ខំដោយសារពេលផ្សារភ្ជាប់បេះដូងជាមួយនាងបង្ហាញម៉ូត គេដឹងស្រេចហើយថានាងជានារីប្រភេទណា។ បើនាងនៅព្យាយាមរក្សាភាពស្អាតស្អំ ក្នុងនាមសុភាពនារី នាយក៏បណ្តោយតាមដោយថយទៅក្បែរតុទឹកលើកកែវមករកចាក់ភេសជ្ជៈ។មាត់ឆ្លើយធ្វើហី៖

មានសង្សារស្អាតអញ្ចឹងទាល់តែនិយាយកុហកខ្លះបានស្រួលតាមដាន!..

នារីសម្លឹងទៅរកបបូរមាត់ញញឹមស្រស់នៃបុរសសម្បុរសជ្រះ។ នាងគ្រឹតនឹងសម្តីឌឺដងរបស់នាយតែនាងមិនឆ្លើយបែរជាដណ្តើមកែវពីគេយកទៅចាក់ទឹក ហើយហុចទៅអោយគេ។ បដិសណ្ឋារកិច្ចរបស់នារីម្ចាស់បន្ទប់ធ្វើអោយគេដឹងស្រេចហើយថា នាងផ្តាប់បម្រើគេដោយមនោសញ្ចេតនាស្មោះស្ម័គ្រ ម្លោះហើយផ្កាញញឹមលេចភ្លែតលើបបូរមាត់នាយសារជាថ្មី មុនពេលគេនិយាយពាក្យអរគុណមកកាន់ទេពធីតាបេះដូង។

ឌីម៉ាញញឹមនិយាយតបទាំងឈ្ងោកមុខចំពោះក្រសែភ្នែកអាណិតស្រលាញ់ដែលនាយកំពុងសម្តែងមក៖

បងKenគួរសមអីម៉េះ?

សេចក្តីស្នេហារបស់ធីតារូបល្អ បានធ្វើអោយបុរសអភិជនម្ចាស់ ផ្កាSaffronរីករាយពេញថ្លើមប្រមាត់តែគេធ្វើជានិយាយមកកាន់នាងស្រាលៗ ៖

ហត់នឿយនឹងកម្មវិធីហើយ ម៉េចមិនព្រមចូលគេង? នឹកអ្នកណា? កូនប្រុសអ្នកតំណាងរាស្ត្រនោះមែនទេ?

ឌីម៉ាបើកភ្នែកមូលក្លុំ។ សម្តីរបស់Kenរំលឹកនាងអោយនឹកឃើញពីរាមនរិន្ទសារជាថ្មី។ នាងដៀងភ្នែកទៅរកបង្អួច ជាទីដែលកាលពីម្សិលនាងឃើញកងការពារពីរនាក់របស់គេកំពុង

យាមតាមដាននៅជាន់ខាងក្រោម។ នៅពេលភាពស្មុគស្មាញលេចឡើងលើផ្ទៃមុខនារីរូបល្អ នាងនឹកក្នុងចិត្តថាម៉េចបានជាKenរំលឹកពីរាមនរិន្ទ ឬមួយថាគេបានដឹងពីរឿងរ៉ាវទាំងឡាយ ដែលបានកើតឡើងចំពោះនាងកាលពីម្សិលមិញដែរ? មែនហើយ បើគេលួចមកតាមនាង ដល់ទីនេះ មានរឿងអីដែលថាអាចលាក់លៀមនឹងគេបាននោះ?

ឃើញនាងស្ថិតនៅក្នុងភាពខ្វល់ខ្វាយ បុរសជាសង្សារវាចាសួរភ្លាមៈ

ម៉េចហើយ?

ឪម៉ាខំគេចវេះ។ នាងធ្វើជានិយាយពីរឿងផ្សេងៈ

បងKenមកដល់បាលីតាំងពីពេលណា?

បុរសថយទៅពាក់កណ្តាលអង្គុយពាក់កណ្តាលឈរលើជ្រុងតុហើយនិយាយផ្ទាន់មកកាន់ សង្សារដោយរក្សាកែវទឹកនៅនឹងដៃៈ

មកទាន់ពេលដែលពួកប្រុសឡូយកំពុងនាំគ្នាពពាក់ពពូនញ៉ែសង្សារបង!

នាងវេភ្នែកហាក់ព្រួយបារម្ភនៅពេលបុរសម្ចាស់ចិត្តនិយាយបញ្ឆិតបញ្ឆៀងជាលើកទី២នេះ។ បបូរមាត់ដែលញញឹមស្រស់បង្ហាញថាគេកំពុងនិយាយលេង តែខ្សែភ្នែកគេដែលកំពុងផ្តោត មកលើភក្ត្រនាង បង្ហាញផ្សេងថា គេកំពុងមើលអោយដល់ជម្រៅចិត្ត និងភាពភក្តីរបស់នាង ដែរ។ មិន ចង់អោយការសង្ស័យអូសបន្លាយទៅវែងឆ្ងាយ ធីតាបង្ហាញម៉ូត និយាយស្រាលៗ ទៅកាន់គេៈ

-តែគេមិនបានខ្វល់នឹងពួកទាំងហ្នឹងទេ! បងKenនិយាយបញ្ឆិតបញ្ឆៀងធ្វើអី?

Kenញញឹមជំនួសចម្លើយគេដាក់កែវចុះទៅលើតុវិញ...រួចឈ្ងោកសម្លឹងនារីដែលឈ្ងោកមុខ ជាប់មិនហ៊ានសម្លឹងខ្លួនតបវិញ។

ឪម៉ាបើកត្របកភ្នែកសម្លឹងមកបុរសដែលនៅកៀកបង្កើយក្នុងភាពស្ងៀមស្ងាត់។ នៅពេល នាងមិនទាន់រកនឹកឃើញថានឹងនិយាយទៅកាន់នាយដូចម្តេចទៀតដើម្បីអោយនាយកាន់តែ ជឿចិត្តនោះKenនិយាយស្រាលៗក្បែរត្រចៀកនាងៈ

រៀបចំខ្លួនទៅជួបគេទៅ!

ឌីម៉ាងើបមុខភ្លែតដោយភ្ញាក់ផ្អើល។ នាងបើកភ្នែកមូលក្លុំសម្លឹងបុរសម្ចាស់ចិត្តនៅ ចំពោះមុខ ខណៈដែលទឹកមុខគេគ្មានត្រង់ណាបង្ហាញថាគេកំពុងនិយាយលេងសើចនោះ។ នាងសួរវិញបន្ទាន់៖

បងKen ថា ម៉េច?

Ken ពាណិជ្ជករផ្នែកលោហធាតុ វ័យក្មេងដ៏មានកេរ្តិ៍ឈ្មោះក្នុងទីផ្សារមូលបត្រកម្ពុជាបានជួបស្គាល់គ្រូបង្ហាញម៉ូតកេតឌីម៉ាកាលពី២ខែមុន នៅពេលដែលនាងត្រូវបានជ្រើសរើសឲ្យមកថតផ្សព្វផ្សាយផលិតផលមួយចំនួន របស់ក្រុមហ៊ុន Cam Steelរបស់ខ្លួន។

បុរសសង្ហា និងស្រីស្អាតត្រូវបានរៀបចំអោយជួបគ្នា ក្រោមការរចនាទុករបស់ព្រហ្មលិខិតរហូតដល់ពន្លកស្នេហា ចិត្តនិងចិត្តលេចត្រួយ និងលូតលាស់យ៉ាងឆាប់រហ័សតាមធម្មជាតិនៃយុវវ័យ។

ក្នុងបេះដូងកេតឌីម៉ាដែលត្រូវការតែសេចក្តីស្មោះជាទុននៃជីវិតបានចារទុកពាណិជ្ជករវ័យក្មេងជាម្ចាស់តាំងពីពេលដែលKenប្រាប់នាងថា នាងគឺជានារីតែម្នាក់គត់ដែលគេសម្រេចចិត្តចែករំលែកក្តីស្រមៃ និងអនាគត។ ត្រឹមថ្ងៃដែលនាងបានជួបគេ នាងបានចាត់ទុកថាទេវតានៅមានយុត្តិធម៌ខ្លះចំពោះនាងដែលចុងក្រោយបានអោយនាងជួបបុរសម្នាក់នេះសម្រាប់ប៉ះប៉ូវសងនូវទុក្ខសោកដ៏វែងអន្លាយរាប់ទាំងការទៅចំណាយមួយរាត្រីជាមួយមនុស្សដែលនាងមិនធ្លាប់ស្រលាញ់នោះផង។ទោះបីនោះជាអតីតកាលដ៏ទុក្ខព្រួយ ដែលកើតមានឡើងតាំងពីមុនពេលឌីម៉ាបានជួបKenទៅទៀត ប៉ុន្តែពេលដែលលឺគេនិយាយពីរាមនរិន្ទនាងបារម្ភណាស់បារម្ភខ្លាចថាគេដឹងរឿងនោះហើយអាក់ អន់ស្រពន់ចិត្ត។ មិនទាន់បាត់ខ្វល់ផងស្រាប់តែគេលាន់មាត់អោយ នាងចេញទៅ ជួបរាមនរិន្ទតាម ការណាត់នៅ Amandariទៀតតើមានន័យថាម៉េចវិញ? ឬមួយគេដឹងរឿងនាងកាលពីអតីតកាលអស់ហើយ?

បុរសសង្ហានៅជិតបង្អើយហាក់យល់ពីអារម្មណ៍តក្កមាររបស់ស្រីស្នេហ៍។ គេបន្លឺឡើងតិចៗ ល្មមតែឮពីរនាក់៖

ក្រែងសន្យាថាជួបបងមែនទេឌីម៉ា? ឱកាសមកដល់ហើយ! អូនអាចចូលទៅជិតវាបានចាំអីទៀត?

កេតឌីម៉ាបើកភ្នែកមូលក្លំ។

នាងនៅចាំច្បាស់ណាស់ថានាងមានកាតព្វកិច្ចសំខាន់មួយតាំងពី នៅភ្នំពេញគឺធ្វើយ៉ាងណាចូលទៅជិតបុរសដ៏មានឥទ្ធិពលមកពីគ្រួសារអ្នកនយោបាយដ៏ល្បីឈ្មោះ គឺរាមនរិន្ទនេះឯង។ វត្ថុបំណងសំខាន់ក្នុងគម្រោងការណ៍នេះគឺធ្វើយ៉ាងណាតាមដានអោយដឹងរាល់សកម្មភាពការងាររបស់នាយដែលអាចជាឧបសគ្គដ៏សំខាន់សម្រាប់Kenម្ចាស់ចិត្តនាង។

Kenបានអោយនារីបង្ហាញម៉ូតដឹងថា រាមនរិន្ទបានប្រើប្រាស់អំណាចរបស់ឪពុកជាតំណាងរាស្ត្រ និងកេរ្តិ៍ឈ្មោះសេសសល់របស់ម្តាយក្នុងក្រុមប្រឹក្សាអភិវឌ្ឍន៍ជាតិសម្រាប់រាំងស្ទះការងារវិនិយោគសុចរិតនានារបស់វិនិយោគិនឯទៀត ឯKenក៏ជាអ្នករងគ្រោះម្នាក់ក្នុងចំណោមនោះ។

ដើម្បីអនាគត និងជួយសម្រេចគោលដៅរួមរបស់ម្ចាស់ស្នេហ៍ដែលស្គាល់គ្នាត្រឹមតែពីរខែ ហើយដែលគេបានទម្លាក់ឋានៈមកប្រគល់បេះដូងដល់នារីកំព្រាគ្មានទីពំនាក់ដូចខ្លួន ឌីម៉ាបានតាំងចិត្តថានឹងសម្រេចគម្រោងការនេះ អោយKenអោយខាងតែបានទោះបីក្នុងជាតិនេះនាងមិនដែលមានបំណងចង់ជួបមុខរាមនរិន្ទជាលើកទី២ក៏ដោយ។

-តែអូនមិននឹកស្មានថាគេមកបាលីដែរទេបងKen! ពេលនេះប្រចុចញ៉ុចណាស់អូនគិតអីមិនចេញមែន។

នាងឆ្លើយតបចំពោះពន្លឺភ្នែកមុតថ្លារបស់បុរសម្ចាស់ចិត្តដែលនៅរង់ចាំចម្លើយ។ Kenយល់ចិត្តទន់ជ្រាយ និងភ័យព្រួយរបស់នារីក្រមុំ។ នាយលូកដៃទៅលើកអញ្ចាលីទាំង១0របស់នាងមកកាន់ជាការផ្តល់កម្លាំងចិត្តហើយនិយាយពន្យល់៖

អ្វីៗខុសពីផែនការ! វាស្រាប់តែបង្ហាញខ្លួននៅទីនេះ! យើងក៏ត្រូវតែបត់បែន!

ឌីម៉ាឈ្ងោកមុខទាំងតឹងទ្រូង។នាងនិយាយម្នាក់ឯងក្នុងចិត្ត៖

-តែបងKenមិនដឹងទេថា អូនធ្លាប់គេងជាមួយគេ ហើយរហូតមកត្រូវមីងកុលាបលេងបីសន្លឹកទៀត!បើលើកនេះអោយអូនទៅជួបគេតាមការណាត់ អូនមុខតែស្លាប់ក្រោមដៃគេហើយ! បើបងKenដឹងរឿងពិតវិញ តើនៅបណ្តោយអោយអូនទៅវេទនាក្រោមដៃគេដែរអត់?

នាងបានត្រឹមគិតតែនិយាយក៏មិនចេញសោះដូចពាក្យចាស់ថាហាស្លាក់ខ្ទាក់ស្លែងស្ដោះត្រូវទ្រូងឯងព្រោះគេមិនដឹងថានាងមិនមែនជាស្រីក្រមុំបរិសុទ្ធព្រោះតែធ្លាប់ទទួលលុយរាមនរិន្ទមកសង្គ្រោះប្អូនឡើយ។

ឱម៉ាអើយឱម៉ា!សង្សារឯងគេស្មានថាឯងមិនដែលមានអីៗជាមួយប្រុសអ្នកនយោបាយនោះបានជាគេហ៊ានអោយឯងទៅជិតគេដើម្បីស៊ើបការណ៍ ចុះបើគេដឹងវិញ តើគេនៅស្រលាញ់ឯងទៀតដែរអត់?

**ភាគទី១**

នាងប្រឹងនិយាយបន្លប់ទៅ រកហេតុផលផ្សេង៖

បងKen! ទោះយ៉ាងណាគេមកណាត់ខ្ញុំទៅជួបនៅកន្លែងអញ្ចឹង បងKenមិនខ្លាចថា រាមនរិន្ទអាចនឹង.....

យល់ចិត្តនារីស្លូតត្រង់ បុរសអ្នកជំនួញតបវិញភ្លាម៖

គេមិនអាចធ្វើអីអូនបានទេកេតឱម៉ា! បងមិនឲ្យសង្សារបង ត្រូវមនុស្សអាក្រក់ដូចវា ជាន់ឈ្លីបានជាដាច់ខាត! អូនទុកចិត្តបងអត់?

នាងងើបមុខសម្លឹងគេ។ ពន្លឺភ្នែកស្រទន់ស្លូតបូតរបស់បុរសអភិជន បានបង្កើតភាពកក់ក្ដៅនិងកម្លាំងចិត្តទ្វេឡើងអោយនារីរូបល្អ។ នាងទទួលស្គាល់ថា Kenប្រាកដជាគិតបានល្អិតណាស់មុនពេលសំណូមពរអោយនាងទៅជួបបុរសដែលនាងមិនចូលចិត្តនោះ ម្ល៉ោះហើយនាងឆ្លើយភ្លាម៖

ប្រាប់មក! បងKenឲ្យអូនធ្វើម៉េចខ្លះ? អូនទៅជួបគេនោះភ្លាម!

Kenញញឹម គេឱនទៅរកថ្ពាល់នាងជាសញ្ញាថាពេញចិត្តចំពោះភក្ដីភាពរបស់ស្រីស្នេហ៍ តែត្រូវនាងគេចចេញតាមសភាវៈរបស់នារីវ័យក្រមុំអៀនប្រៀន។ គេក៏មិនមែនជាមនុស្សមានៈបំពានលើអារម្មណ៍ស្រស់ស្រីដែរ ម្ល៉ោះហើយអភិជនប្រឹងទប់ចិត្តស្រើបស្រាលនិយាយតបវិញ៖

-ឪម៉ា! អោយតែមានមធ្យោបាយចូលទៅកៀករាមនរិន្ទ យើងត្រូវតែចាប់ឱកាសឲ្យជាប់! ការណាត់ជួបយប់នេះជាឱកាសមួយ! បើអូនមិនទៅ ម៉េចនឹងដឹងថាវាកំពុងធ្វើអ្វី និងគិតអ្វី?

នារីងក់ក្បាលផ្ងក់ៗតាមសារជាតិស្មោះត្រង់ និងមិនឆ្លាតវៃ។ គ្រប់ពាក្យសម្ដីរបស់បុរសកំពូលដួងចិត្ត នាង គ្មានអ្វីត្រូវសង្ស័យ ឬប្រកែកប្រណាំងទេ តែភ្លាមនោះនាងនឹកឃើញដល់រឿងមួយ។ នាងរបូតមាត់ទាំងទឹកមុខបារម្ភ៖

-បងKenឡើងមកដោយរបៀបណា? មានអ្នកណាឃើញបងទេ?

Kenញញឹមបង្ហាញភាពស្រស់សង្ហាលើផ្ទៃមុខ៖

បើបងអោយពួកបរិវាររាមនរិន្ទឃើញបងនោះ ផែនការយើងមិនចប់ទៅហើយ?

នារីនឹងនចិត្តវិញនៅពេលគេនិយាយយ៉ាងដូច្នេះ។ នាងដឹងថាKenអាចវាងវៃលើចំណុចទាំងនេះព្រោះថាបើវត្តមានគេនៅបាលីក៏ដូចជាទំនាក់ទំនងគេ និងនាងត្រូវបានអ្នកទី៣ដឹងនោះ ផែនការគេ និងនាងត្រូវចប់ដូចអំបិលត្រូវទឹក។ នាងគ្មានពេលពិចារណាទេថា តើគេអាចជូនផ្កាSaffronនាងដោយរបៀបណាដែលមិនឲ្យអង្គរក្សពីរនាក់របស់រាមនរិន្ទនៅខាងក្រោមមិនដឹងកាលពីម្សិលមិញហើយថ្ងៃនេះតើគេប្រើវិធីបែបណាក្នុងការឡើងមកជួបនាង នាងគ្រាន់តែដឹងថា សម្រាប់ពួកអ្នកមានដូចKenអ្វីក៏គេអាចធ្វើបានដែរ។

ធីតារូបល្អស្រវារកទូរស័ព្ទបម្រុងចុចតែត្រូវKenចាប់ជាប់ជាមួយប្រយោគសំនួរ៖

-អូនចុចទៅអ្នកណា?

នាងឆ្លើយតបវិញដោយភ្នែកមូលក្លំ៖

-ទៅរកមីងកុលាប! គាត់ជាមនុស្សដែលរាមនរិន្ទប្រើសម្រាប់ទាក់ទងមកខ្ញុំ!

តែនាងមិនបានប្រាប់ទេថា ស្ត្រីនោះក៏ជាស្ត្រីដែលបាននាំយករាត្រីទីមួយរបស់នាងទៅឲ្យរាមនរិន្ទដែរនោះទេ តាំងពីនាងមិនដែលស្គាល់Ken។ គិតដល់ចំណុចនេះ នាងឈ្ងោកមុខដោយអៀនខ្មាសមិនហ៊ានប្រឈមនឹងក្រសែភ្នែកប្រុសស្នេហ៍ឡើយ។ តែភ្លាមនោះនាងឮគេនិយាយមកតិចៗ៖

-ស្ត្រីនោះដេកលក់បាត់ហើយ!

នាងងើបមុខសម្លឹងគេ រកសួរវិញដែរថាហេតុអ្វីគេដឹង។ ប៉ុន្តែពន្លឺភ្នែក និងស្នាមសំណើចតិចៗលើបបូរមាត់នាយ ល្មមអាចឲ្យនាងស្មានបានថា Kenបានរកវិធីអោយស្រីនោះដេកលក់បាត់ ហើយទើបរហូតដល់ពេលនេះនៅតែមិនឃើញគាត់ឡើងមកអង្វរនាងរឿងទៅជួបរាមនរិន្ទនៅ Amandari។ នាងទទួលស្គាល់ថា Kenគិតបានល្អិតសព្វតែរឿង ដូច្នេះនាងគ្មានអ្វីត្រូវបារម្ភ ឬរារែកក្នុងការចេញទៅជួបរាមនរិន្ទដើម្បីសម្រេចបំណងសង្សារកំពូលដួងចិត្តនោះឡើយ។

នាងងក់ក្បាលតិចៗ៖

-អូនរៀបចំខ្លួនទៅAmandariឥឡូវនេះ ព្រោះកៀកម៉ោងណាត់ហើយ!

Kenមិនបានឆ្លើយតបទេ តែកូនដបតូចមួយត្រូវបានហុចមកចំពោះមុខនាង៖

-របស់នេះបានធ្វើអាយមីងកុលាបដេកលក់លែងរំខានអូន វាក៏អាចអោយរាមនរិន្ទដេកលក់ពេញមួយយប់ដែរ បើអូនយល់ថាវាចាំបាច់!

ឱម៉ាបើកភ្នែកមូលក្លំសម្លឹងកូនដបទំហំប៉ុនពីរធ្នាប់ដៃដែលកំពុងត្រូវបានហុចមក។ នាងលូកដៃទទួលដោយបេះដូងចាប់ផ្ដើមលោតញាប់។ នាងយល់ពីន័យរបស់Ken។ គេចង់និយាយថាដបថ្នាំនេះនឹងជួយនាងអោយអាចគេចផុតពីអំណាចតណ្ហារបស់រាមនរិន្ទបាន។

Kenសម្លឹងនាងយ៉ាងមុតហើយបន្លឺបន្ត៖

-អរគុណណាស់ម្ចាស់ចិត្តបង ដែលប្រឹងប្រែងដើម្បីបងដល់ថ្នាក់នេះ!

នារីស្វាងចេញពីភាពភ័យព្រួយ នាងប្រឹងញញឹមលួងចិត្តប្រុសស្នេហ៍។ ទោះការងារនេះជាការងារមិនសមនឹងចរិតលក្ខណៈរបស់នាង តែស្នេហាគឺជាការលះបង់មែនទេ?

កេតឱម៉ាខំលើកទឹកចិត្តប្រុសស្នេហ៍ ៖

-នរណាប្រើគេនោះធ្វើបាបបងKen? ខ្ញុំត្រូវតែអាក្រក់ជាមួយគេអញ្ចឹងហើយ!

Kenញញឹមនៅពេលសូម្បីតែនារីសារជាតិស្លូតត្រង់ម្នាក់ក៏ព្រមលុះក្រោមផែនការរបស់ខ្លួន។ នាយចង់ស្រវាឱបនាងតែពេលវេលាមិនអនុគ្រោះឡើយ ព្រោះសារជាអក្សរបានផ្ញើមកក្នុងទូរស័ព្ទដៃរបស់គេ។ គេឱនអានវា ហើយងើបមុខមកប្រាប់ឱម៉ា៖

-រាមនរិន្ទឲ្យមនុស្សមកទទួលអូនហើយ! ឆាប់ឡើងទៅ!

នារីដកដង្ហើមឃូរបន្លប់ភាពតឹងតែង។ នាងដឹងថាបណ្ដាញរបស់Kenនៅខាងក្រោមប្រហែលឃើញកូនចៅរាមនរិន្ទទើបនឹងមកដល់បានជាគេផ្ដល់ដំណឹងមកភ្លាម។ នាងទទួលស្គាល់ថាកាលបើបណ្ដាញរបស់ម្ចាស់ចិត្តមានកាន់តែច្រើន នាងកាន់តែមានអារម្មណ៍ថាមានសុវត្ថិភាព។ នាងងក់ក្បាលទន្ទឹមនឹងពេលKenនិយាយឡើងជាចុងក្រោយ៖

-បងចេញទៅហើយ! កុំឲ្យគេឡើងមកទាន់!

ខ្សែភ្នែកគេដែលចោលមករកនាងមុនពេលចាកចេញទៅហាក់ដូចជានិយាយប្រាប់ជាស្រេចហើយថាកុំអោយថ្លោះធ្លោយផែនការលើកនេះអោយសោះ។

នាងជូនគេដល់មាត់ទ្វារ ហើយត្រឡប់មកវិញទាំងបេះដូងចាប់ផ្ដើមញាប់ញ័រ។ ទីបំផុតនាងត្រូវតែទៅAmandariជួបប្រុសម្នាក់នោះ។

នាំកាយទៅដល់ទ្វារទូសំលៀកបំពាក់មិនទាន់ទាំងបានជ្រើសរើសមួយយកមកកាន់ផងស្នូរគោះទ្វារលាន់ឡើងតុៗ។ នារីក្រឡាស់ភ្នែកដោយភិតភ័យតែនាងចាំបាច់ត្រូវទៅកាន់មាត់ទ្វារ។

ទ្វាររបើកក្រោមការអនុញ្ញាតរបស់ម្ចាស់ស្រីនៃបន្ទប់សណ្ឋាគារ។ នាងសម្លឹងទៅខាងក្រៅប្រទះឃើញបុរសពីរនាក់ កំពុងឈរអមបុរសម្នាក់ផ្សេងទៀតដែលមានអាកប្បកិរិយាញញឹមពព្រាយយកចិត្តនៅនឹងមុខបន្ទប់។

-ខ្ញុំមានភារកិច្ចមកទទួលអ្នកនាងឌីម៉ាទៅAmandari!

ឌីម៉ាញញឹមស្ងប់ស្ងាត់ត្រឡប់ទៅកាន់នាយBirdដែលនាងទើបតែបានជួបជាលើកដំបូង។ បបូរមាត់ស្រស់ស្អាតបង្ហើបតបទន់ភ្លន់៖

-ទុកពេលឲ្យខ្ញុំ១៥នាទីណា!

**វគ្គទី៥**

**រាត្រីនៅAmandari**

ទ្រនិចនាឡិកាចង្អុលដល់ម៉ោង៩និង៣០នាទីយប់ រាមនរិន្ទដកភ្នែកពីកញ្ចក់កុំព្យូទ័រជាមិត្តសំណព្វជាមួយនិងឃ្លាបង្ហើយចុងក្រោយ "កូនយល់ហើយ!ជម្រាបលាលោកពុក"។

គេពត់ខ្លួនងាកមករកមនុស្សក្រោមបង្គាប់ដែលនៅឈរក្បែរជ្រុងម្ខាងនៃបន្ទប់សណ្ឋាគារ ប្រកបដោយក្បូរក្បាច់រចនាបែបប្រពៃណីជនជាតិថ្នាដ៏ប្រណិត។

-រឿន! យើងត្រូវទៅប៉ាពួ!

នាយរឿនស្ទុះចូលមកត្រង់ត្រាប់ស្តាប់បង្គាប់នាយចៅហ្វាយដោយមិនមានហ៊ាន ថាស្តីសួរត្រឡប់យ៉ាងណាឡើយ រហូតដល់រាមនរិន្ទបន្លឺបន្ថែម៖

-លោកពុកមានប្រសាសន៍ថា នៅភ្នំពេញក៏កំពុងមានអ្នកនិយាយពី**ឥន្ទប្បដិមា**ហ្នឹងច្រើនដែរ! យើងអត់មានពេលយូរទេ!ចាត់ចែងកាន់តែឆាប់កាន់តែល្អ!

នាយរឿនលំអោនកាយទទួលបទបញ្ជា៖

-បាទ! ខ្ញុំទៅរៀបចំភ្លាមទាន!

រាមនរិន្ទងក់ក្បាលផ្ងក់ៗលូកដៃចុចបិទឧបករណ៍បច្ចេកវិទ្យាសម្រាប់ទំនាក់ទំនងរបស់ខ្លួន។ ប្រហែលជាទើបតែនឹកឃើញ គេចាប់ចងចិញ្ចើមងើបមុខមើលទ្រនិចនាឡិកា។ យល់ចិត្តចៅហ្វាយ នាយរឿនដើរមកលំទោនរាយការណ៍៖

-កេតឌីម៉ាមកដល់ហើយ! នៅបន្ទប់អាហារទាន!

រាមនរិន្ទបញ្ចេញភាពស្រស់ស្រាយតាមពន្លឺភ្នែក។ គេក្រោកឈរដើរសំដៅទ្វារតែមាត់និយាយទៅរកមនុស្សក្រោមបង្គាប់៖

-ទៅធ្វើការចុះ!

នរៈអភិជនបោះជំហានចាកចោលមនុស្សជំនិតឆ្ពោះទៅរកបន្ទប់អាហារពិសេសដែលត្រូវបានរៀបចំរួចជាស្រេច។ កាត់តាមបណ្តោយកូនឧទ្យានផ្កាម្លិះសក្បុសដូចព្រិល ពិដោរនៃលំអងបុប្ផាដ៏ក្រអូបស្រទន់ បានជះចោលគន្ធមកលួងលោមបំបាត់ភាពហត់នឿយរបស់ម្ចាស់ប្រុសនៃទីសំណាក់ផ្តាច់មុខ Exclusive Roomដែលស្ងប់ស្ងាត់តែស្រស់ត្រកាល។

ចង្កៀងគោមល្អវិចិត្ររាប់សិបគ្រឿងត្រូវបានរៀបពង្រាយតាមដងផ្លូវ ស្វាគមន៍ដំណើរនៃបុរសមានអំណាច ប្រៀបបីដូចជាបុរាណវិថីភ្លឺត្រចង់ក្នុងភាគនិទានរបស់អារ៉ាប់នាបុព្វកាលសម័យស្វាគមន៍រាជសុណិសាអាឡាដាំង។

យុវបុរសនាំរាងកាយស្រស់មាំទាំមកដល់បន្ទប់អាហារស្ថាបនាដោយឈើPineនៅប្រឋនឹងមាត់ទឹកដៃសមុទ្រក្រោមជំនោររំភើយនារាត្រីកាល។

នៅក្បែរសង្ហារឹមពណ៌ខ្លឹមចន្ទន៍ អមលំអដោយផ្ទាំងស្បៃពណ៌សរេរាំរេចិតាមកម្លាំងខ្យល់សមុទ្រ អ្នកប្រទះឃើញសរសៃសក់ទន់ វែង ដែលមុននេះបានរេរាំលើឆាកបុប្ផាអាស៊ីយ៉ាងទាក់ភ្នែកនោះ។ តរុណីម្ចាស់ក្រុមកិន្នរីកំពុងអង្គុយបែរខ្នងសម្លឹងទៅផ្ទៃទឹកពណ៌ទឹកមាសក្រោមស្រមោលភ្លើងគោមលំអអមបណ្តោយច្រាំង។ នាងហាក់ស្លុងអារម្មណ៍ជាមួយប្រណីតភាពនៃសិល្បៈតុបតែងដ៏កំពូលរបស់ Amandari ប៉ុន្តែស្នូរជើងធ្ងន់ៗរបស់បុរសមាឌធំ បានទាញអារម្មណ៍នាងអោយត្រឡប់ចូលមករាងកាយវិញ។

តរុណីភ្ញាក់ព្រើតហើយស្ទុះក្រោកពីបង្គុយ។ នាងងាកបែរក្រោយសន្សឹមៗស្វាគមន៍បុរសដែលតាមពិតនាងត្រូវបានបង្ខំអោយមកជួបគេតែប៉ុណ្ណោះ។ ស្នាមញញឹមស្រស់សង្ហាលើបបូរមាត់រាមនរិន្ទនៅតែមិនរុះរោយដូចកាលពីរាត្រីមួយដែលស្ត្រីមេអណ្តើកបាននាំនាងទៅអោយគេ។ នាងបង្ខំបបូរមាត់អោយបណ្តុះចេញនូវផ្កាសំណើចតែពន្លឺភ្នែកដ៏ក្រៀមស្រពោនរបស់នាងបានក្បត់នាងស្រេចទៅហើយ។

លោកប្រុសរាម!

រាមនរិន្ទចូលទៅកៀកនឹងនាង។ រូបស្បែស្រាលវែងរបស់កេតឌីម៉ាហើរមកបោកប៉ះនឹងរាងកាយអ្នកដោយសារអំណាចវាយោ។ ជំនួសឲ្យវាចាតបនាយលូកដៃទៅក្រសោបចង្កេះតូចរាវដែលនៅចំពោះមុខព្រោះត្រូវលង់ក្រោមបរិយាកាសដ៏ទាក់ទាញជាស្រេចទៅហើយតាំងពីវិនាទីដំបូងដែលចូលមកដល់ទីនេះ។

ធម្មតាកញ្ញាបង្ហាញម៉ូតត្រូវតែគេចពីរង្វង់ដៃនាយ តែពេលនេះហេតុអ្វីនាងបែរជាមិនហ៊ានតែប្រែទៅជាស្រទន់ឡាំងកាំង?

មកពីនាងដឹងថាខ្លួនមកទីនេះដើម្បីអ្វីហើយក្នុងនាមអ្វី ម្ល៉ោះហើយបើនាងគេចចេញពីនាយមានតែបណ្តោយអោយផែនការនានាត្រូវរលាយដូចក្រមួនត្រូវថ្ងៃ?

សរសៃសក់អ្នកគ្រូរូបល្អផាត់ប៉ះនាសានិងបបូរមាត់នរៈអភិជនដែលកំពុងឈ្ងោកសម្លឹងមុខនាង។បបូរមាត់កេតឌីម៉ាប្រែទៅជាញ័រ តិចៗ និងចង្វាក់ដង្ហើមកាន់តែញាប់លើផែនទ្រូងស្រស់ព្រហើន

បានបញ្ជាក់អោយអ្នកដឹងជាស្រេចហើយថានាងកំពុងភ័យព្រួច។

-បែកយូរម្ល៉ឹងៗ នឹកគ្នាខ្លះទេកេតឌីម៉ា?

កេតឌីម៉ានឹកនារាមនរិន្ទមិនទាន់បានដឹងអស់ទេពីល្បិចកលរបស់មីងកុលាបម្ល៉ោះហើយវិធីមានតែមួយគត់គឺនាងចាក់បណ្តោយប៉ុន្តែចុះបន្ទាប់មកទៀតនាងគួរធ្វើយ៉ាងណាបើមិនទាន់អីផង នាងស្ថិតក្នុងរង្វង់ដៃគេរួចទៅហើយ?

កណ្តោលបរិវេណធម្មជាតិស្ងាត់ជ្រងំ មានតែពីរនាក់តទល់ បើមិនប្រញាប់ប្រើប្រាជ្ញាដោះស្រាយបញ្ហា មានតែទ្រាំស្លាប់តាមយថាកម្ម?

គិតហើយនាងក៏នឹកភ្លែតដល់ដបថ្នាំដែលបានមកពីKenម្ចាស់ចិត្ត។ បើពេលនេះរាមនរិន្ទអាចលង់លក់ដូចអ្នកស្រីកុលាប យប់នេះនឹងរំលងទៅដោយសុវត្ថិភាព។ នាងហើបមាត់ឆ្លើយតបតិចៗ៖

-អាហាររៀបចំរួចហើយលោកប្រុសរាម! សូមអញ្ជើញ!

រាមនរិន្ទងាកមើលទៅភោជនាហារដែលត្រូវបានផ្ទិតផ្ទង់ទ្រង់គ្រឿងលើតុឈើខ្លឹមរលោងប៉ប្រះនឹងផ្ទៃ ទឹក។ នៅទីនោះនរៈមិនប្រទះឃើញមានអ្នកចាំទទួលបដិសណ្ឋារកិច្ច ណាម្នាក់ទេមានន័យថានាងមានចេតនាអោយពួកគេចាកចេញ?

នារីចាប់ដៃគេថ្នមៗឲ្យលែងចេញពីចង្កេះនាង។ បបូរមាត់នាងខំញញឹមនៅពេលដែលបុរសកំពុងមានវត្តមានចំពោះមុខអាចថាសង្ស័យពីការមិនស្និទ្ធស្នាលរបស់នាង។ នាងប្រឹងនិយាយបន្លប់៖

-យប់ជ្រៅហើយ! លោកនៅមិនទាន់បានពិសាអីទៀត? ធ្វើការហត់នឿយអីថ្នាក់នេះ?

បុរសញញឹមសម្លឹងទៅកាន់បបូរមាត់ដែលប្រឹងវាចាខុសចិត្ត។ នាងប្រឹងយ៉ាងណារាមនរិន្ទនៅតែដឹង ថានាងកំពុងរកស្នៀតយករួចខ្លួនតែប៉ុណ្ណោះ។ តែគេធ្វើពើហើយពោលសួរវិញ៖

-មកពីយើងហ្នឹងដែលមកយឺតណាត់ធ្វើអី? មានអ្នកគាំទ្រតាមសុំហត្ថលេខាច្រើនមែនទេ?

ធីតាដៀងភ្នែករំពឹងគិតពាក្យឆ្លើយតប។ គ្មានអ្វីប្រសើរជាងដាក់ខ្លួនជាមនុស្សក្រោមបង្គាប់នាយនោះទេ៖

សូមទោស! គឺមកពីហត់នឿយរឿងលើឆាកពេក ក៏គេងភ្លេចខ្លួនលក់ជ្រុលទៅ!

ដោយសារនាយBirdបានរាប់តាំងពីម្សិលមិញអស់ហើយ រាមនរិន្ទដឹងច្បាស់ណាស់ថា នាងបង្ហាញមុ៉តមកកាន់ទីនេះទាំងស្ទាក់ស្ទើរព្រោះតែចង់លុបលាងទោសកំហុសអោយយាយមេអណ្ដើកតែប៉ុណ្ណោះ។ នាយកាន់តែគិតរឹតតែចង់ដឹងថាតើនាងមានវិធីបែបណាដើម្បីជួយលាក់ទោសកំហុសស្ត្រីចំណាស់នោះគេក៏ចាក់បណ្ដោយ។

ល្អហើយ! បរិយាកាសនៅទីនេះគ្រាន់បើទេតើ! យប់នេះប្រហែលអាចគេងលក់ស្រួល!

បេះដូងនាងចាប់ផ្ដើមលោតញាប់នៅពេលឮប្រយោគនេះ តែនាងនៅតែរក្សាទឹកមុខញញឹមស្ងប់ស្ងាត់។

តោះយើងញ៉ាំបាយជាមួយគ្នាម្ដង!

គេដើរចុះទៅកាន់តុអាហារដែលមានជណ្ដើរបីថ្នាក់ទៀតទើបចុះដល់។ នាងត្រូវដើរតត្រុកទៅតាមពីក្រោយគេទាំងពិភាល់ក្នុងចិត្ត។

នៅពេលបុរសសង្ហាដាក់បង្គុយក្បែរតុអាហារស្រួលបួលនាងក៏ស្ថិតនៅតទល់នឹងគេ។

កាយវិការចាប់ម្ហូបដាក់ចានរបស់ធីតារូបល្អ ប្រតិបត្តិទៅក្រោមក្រសែភ្នែកអណ្ដែតអណ្ដូងបុរសអភិជនតែដោយសារបបូរមាត់របស់គេតែងតែចោលនូវស្នាមញញឹមជានិច្ចនាងពិបាកដឹងណាស់ថាតាមពិតនោះគេកំពុងគិតពីអ្វី?។

**ភាគទី១០**

នៅចំពោះមុខកំលោះរូបស្អាត ជាមនុស្សមានឥទ្ធិពលដែលមិនខ្វះនារីប្រាថ្នាក្លាយជាទីចាប់អារម្មណ៍របស់គេហេតុអ្វីបានជាកេតឌីម៉ាបែរជាច្របូកច្របល់រកផ្លូវគេចវេះ ?

ប្រការសំខាន់គឺតាំងតែពីដំបូងមកនាងយល់ថារាមនរិន្ទជាមនុស្សមិនដែលមានស្នេហ៍ស្មោះឲ្យស្រី ណាឡើយ បើប្រៀបធៀបទៅនឹងKen ដែលជាយុវវ័យនៃត្រកូលអភិជនដូចគ្នា។

នាងនឹកឃើញដល់ពេលមួយដែលអ្នកស្រីកុលាបមករកនាង ហើយគាត់និយាយប្រាប់ថា រាមនរិន្ទទាមទារសំណងខ្លួនប្រាណជាថ្នូរ និងប្រាក់ជំពាក់។ នាងបានចំណាយទឹកភ្នែកស្ទើរលង់លិចសង្ខារហើយសច្ចាក្នុងចិត្តថា មនុស្សដែលមើលមកមនុស្សដូចគ្នាទុកដូចសម្ភារៈកំដរអារម្មណ៍ គឺជាសត្រូវរបស់នាងជានិច្ចក្នុងជីវិតនេះ។

ទើបតែពេលថ្មីៗនេះ ដែលអ្នកស្រីកុលាបដែលទឹកដល់ច្រមុះព្រមសារភាពថា កាលពីរាត្រីនោះរាមនរិន្ទមិនបានមានគម្រោងទាមទារភាពបរិសុទ្ធរបស់នាង ថ្នូរនឹងប្រាក់ជំពាក់ក៏ដោយ តែកាលដែលនាយណាត់នាងមកកាន់Amandariនៅរាត្រីនេះបង្ហាញស្រេចហើយថា គេស្ថិតក្នុងចំណោមក្រុមមនុស្សដែលមើលមកស្ត្រីថាជាល្បែងតណ្ហាដូចតែការគិតទុកពីដំបូងមក។

នាងដឹងថាចំពោះមុខប្រុសម្នាក់នេះនាងគ្រាន់តែជាល្បែងម្យ៉ាងដែលគេទិញមកដោយប្រាក់ គេឈប់ត្រូវការនាងដោយបំភ្លេចនាងចោលតាំងពីដណ្ដើមបានភាពបរិសុទ្ធនាថ្ងៃដំបូងម្ល៉េះតែថ្ងៃនេះគេលេងសើចជាមួយនាងសារជាថ្មីព្រោះតែចង់សម្ដែងឫទ្ធិឲ្យមនុស្សគ្រប់គ្នាដឹងថាអ្វីដែលគេឯងយកមិនបានអភិជនសិទ្ធិគុណយកមិនបានរាមនរិន្ទអាចយកបាន។

ឪម៉ាខាំមាត់សង្កត់ចិត្តនៅពេលនាងផ្គាប់បម្រើបុរសម្នាក់នេះ ត្បិតវាសនាចារមកអោយនាងមកស្គាល់ប៉ះមនុស្សនេះមុនពេលជួបមនុស្សល្អដូចជាKen។ កាលណោះបើទេវតាមិនលលេងនឹងនាងហើយបណ្ដោយអោយនាងបានជួបKenមុនពេលប្អូននាងមានជំងឺ ម្ល៉េះសមនាងមិនបាច់ចំណាយកិត្តិយស និងសេចក្ដីថ្លៃថ្នូរព្រមទាំងវត្ថុមានតម្លៃបំផុតក្នុងជីវិតជានារីភេទ ជាថ្នូរនិងអាយុជីវិតប្អូនបែបនេះឡើយ ហើយយប់នេះនាងក៏មិនចាំបាច់មកចំណាយពេលផ្គាប់ចិត្តបុរសម្នាក់ដែលនាងមិនពេញចិត្តអញ្ចឹងនោះដែរ។

- ប្អូនយើង យ៉ាងម៉េចហើយ ?

ប្រយោគសំនួររបស់នរៈយើងកាត់ផ្ដាច់អារម្មណ៍បាចសាចរបស់នាងក្រមុំទាសីស្នេហា។ ធីតាងើបមុខសម្លឹងគេដែលប្រកបដោយភាពរីករាយនៅចំពោះមុខខ្លួន។ នាងចាំបាច់ត្រូវតែញញឹមឆ្លើយតបៈ

- ចាសគឺពេទ្យថាជាសះមួយរយភាគរយហើយ ! ឥឡូវនេះទៅរៀនបានធម្មតា !...

- មានតែពីរនាក់បងប្អូនទេ ? ចុះប៉ាម៉ាក់ ! ?

ឌីម៉ាមិនចង់និយាយរឿងផ្ទាល់ខ្លួនច្រើនប្រាប់បុរសនេះទេ តែនាងចាំបាច់ត្រូវតែតបសំនួរគេ។ នាងពោលយ៉ាងខ្លី ៖

- លោកទាំងពីរស្លាប់ច្រើនឆ្នាំហើយ!

ឃើញនាងស្រងូត នរៈសង្ហាចាប់អាណិតនាង។ គេដឹងថាកាលដែលបង្ខំអោយនាងមកជួបនៅយប់នេះបានប៉ះពាល់ដល់ពេលវេលាផ្ទាល់ខ្លួន និងផ្លូវចិត្តរបស់នាងប្រាកដណាស់ ហើយកាលដែលនាងភាន់ភាំង និងទើសទាល់នៅចំពោះមុខនាយជាធម្មជាតិរបស់មនុស្សស្រី ប៉ុន្តែអ្វីដែលធ្វើអោយនាយនៅតែចង់ជួបនាងនោះគឺដោយសារកាលពីម្សិលនាងមើលទៅរឹងរូសគួរសមក្នុងការបដិសេធអន្ទាក់ស្នេហ៍កណ្តាលចំណោមរបស់សេដ្ឋីក្មេងសិទ្ធិគុណ។

ដែលសំខាន់មួយទៀតគឺនរិន្ទក៏ទើបតែដឹងដែរថា ស្ត្រីមេអណ្តើកនោះបានលេងល្ខោនឆ្កិនភ្នែកបោកប្រាស់ទាំងសងខាង។ ពេលនេះទៀតអ្នកយល់ថាឌីម៉ាដែលដឹងការពិតអស់ហើយ នាងអាចនិងមិនទទួលយកការណាត់ជួបនៅយប់នេះបាន តែនាងនៅតែមក ក៏ដោយសារនាងមិនចង់អោយស្ត្រីចំណាស់នោះទទួលទោស។ តែអ្នកគិតមិនដល់ទេថាបុរសម្ចាស់ផ្កាSaffronជាអ្នកមានអំណាចពិតប្រាកដក្នុងការរុញអ្នកគ្រូបង្ហាញម៉ូតវ័យក្មេងមកអោយអ្នក។

ចំពោះមុខក្រសែភ្នែកស្រងូតនិងម្រាមដៃរាវស្រឡូនដែលនារីខំប្រឹងលើកអាហារមកទំពាយឺតៗហាក់គ្មានរសជាតិ រាមនរិន្ទវាចាប្រាប់នាងស្រាលៗ ៖

-បើថ្ងៃក្រោយ... មានការអ្វីចង់ឲ្យខ្ញុំជួយ... ត្រូវប្រាប់ណ៎ា!

ឌីម៉ានៅសំងំស្ងៀមមិនស្តីមួយម៉ាត់...នាងប្រឹងញញឹមតបគួរសមរួចធ្វើជាទំពាម្ហូបបន្លប់តែចិត្តវិញ...បានប្រាប់ខ្លួនឯងយ៉ាងម៉ឺងម៉ាត់ហើយថា... នឹងមិនធ្វើខ្លួនជាកូនបំណុលរបស់ រាមនរិន្ទជាលើកទី២ទៀតឡើយ ត្រឹមម្តងនេះនាងចាត់ថា វាជាកម្មពៀរពីអតីតជាតិគួរឲ្យរាងចាលទៅហើយ...នាងគ្មានថ្ងៃទទួលជំនួនពីមនុស្សនេះទៀតទេ អ្នកដែលផ្តល់ជំនួយដោយចិត្តមិនបរិសុទ្ធ... ។

ភ្លាមនោះនាងគិតឃើញដល់រឿងផ្សេង ទាំងសិទ្ធិគុណ ទាំងរាមនរិន្ទ ពពាក់ពពូននាំគ្នាមកកាន់កោះបាលីក៏គ្មានអ្វីក្រៅពីត្រេកត្រអាលនឹងសម្រស់ស្រីឡើយមិនដឹងថានឹងមាននារីណាទៀតទេដែលនឹងត្រូវគេជាន់ឈ្លីនោះ ។

គិតបណ្ដើរនាងលូកដៃដួសអាហារបន្ថែមដាក់ទៅអោយរាមនរិន្ទ។ ដោយសារនាងចង់គេចពីការសន្ទនាម្ល៉ោះហើយនាងមិនដឹងធ្វើអ្វីមានតែដួសអាហារនេះបន្តិចនោះបន្តិចដោយច្របូកច្របល់។ រាមនរិន្ទដាក់ស្លាបព្រាចុះ គេញញឹមសម្លឹងកាយវិការស្រីស្អាត រហូតដល់នាងដឹងខ្លួនមកវិញបើកភ្នែកធំៗព្រោះអាហារត្រូវបាននាងដាក់ពោរពាសពេញចាននាយទៅហើយ។

ឪម៉ាស្រឡាំងកាំងដោយសារភាពឆ្គាំឆ្គងនៃបដិសណ្ឋារកិច្ចរបស់ខ្លួនចំពោះបុរសអ្នកមានពិបាកក្នុងការប៉ះប៉ូវវិញណាស់។ ពេលនេះ តើនាងគួរបកស្រាយប្រាប់គេថាម៉េច? ថានាងនៅជាមួយគេតែអារម្មណ៍ហោះហើរអញ្ចឹង ឬយ៉ាងណា។

ខណៈស្រីស្រស់កំពុងភាន់ភាំង អ្នកប្រុសត្រកូលខ្ពស់និយាយមកកាន់នាង៖

-គិតសម្លាប់គ្នាអញ្ចឹងអ្វី?

តាមពិតនរិន្ទគ្រាន់តែចង់និយាយលលេងដែលនាងដួសម្ហូបដាក់អោយនាយទាំងសស្លើតសស្លក់ប៉ុន្តែឪម៉ាបែរជាកាន់តែភ័យព្រោះថានាងមកនេះមិនមែនមកដោយស្មោះមែនហើយពិសេសនាងកំពុងគិតពីរឿងអាក្រក់ៗចំពោះនាយផង។

កំសួលចិត្តតក្កមាបានរុញធីតាអោយឆ្លេឆ្លាមិនដឹងថាត្រូវតបយ៉ាងណាចំពោះក្រសែភ្នែកបុរសចំពោះមុខខ្លួន វិធីដែលនាងជ្រើសរើសមុនគេគឺទាញកែវទឹកយកមកក្រេបពន្យារពេល។

ដំណក់ទឹកត្រូវបានធ្លាក់ក្អឹកចូលដល់បំពង់ក ភាពត្រជាក់ស្រេងបានជួយអោយនាងធូរស្រាលតែបរិយាកាសចំពោះមុខមិនទាន់ស្រាយចេញនៅឡើយទេ។

នាងខំធ្វើទឹកមុខស្លូតបូតទៅកាន់បុរសមានអំណាច។

-សូមទោសផងលោកប្រុសរាម....គឺ...គឺ...

(ឯងចប់ហើយកេតឪម៉ា នេះឬរបៀបផ្គាប់ផ្គុនប្រុសអ្នកមានរបស់ឯង) នាងគិតស្ងាត់ៗក្នុងចិត្ត។ (បងKenអូនអាចធ្វើអីដើម្បីបងបានបើគ្រាន់តែកំដរគេហូបបាយ អូនធ្វើអោយបរិយាកាសក្លាយជាអញ្ចឹងទៅហើយ) នាងទោមនស្សស្ងាត់ៗ។ វាចារាមនរិន្ទលាន់មកសារជាថ្មី ៖

- សុំទោសរឿងណាមួយ? រឿងដួសម្ហូបឬមួយរឿងដណ្ដើមកែវទឹកខ្ញុំយកទៅកេតឪម៉ា?

ហួសចិត្ត...នាងឱនសម្លឹងដៃ ហើយស្រែកយែដោយសារនាងកំពុងក្រេបទឹករបស់នាយអស់មែន។ចំណែកកែវនាងនៅនឹងកន្លែងដើមដដែល។ ដោយសារតែកែវទាំងពីរដាក់នៅទន្ទឹមគ្នាពេកម្ល៉េះហើយក្នុងវិនាទីនៃអារម្មណ៍ច្របល់ នាងបានសាងកំហុសបន្ថែមលើបញ្ហាដែលនៅស្រាយមិនទាន់ចេញ។

រឹតតែវីវរនោះគឺពេលនេះនាងទៅជាបើកភ្នែកលែងចង់រួចទៅហើយ។

ម៉េចក៏ក្បាលប្រែទៅជាធ្ងន់អីធ្ងន់យ៉ាងនេះ?

រូបរាងរាមនរិន្ទនៅចំពោះមុខចាប់ផ្តើមទៅជាព្រាល។ ឪម៉ាយកដៃញីភ្នែកក្នុងពេលដៃក៏ហាក់បីអស់កម្លាំងលែងចង់ស្តាប់បញ្ជា។

កើតអីឪម៉ា?

សូរសំឡេងរាមនរិន្ទលាន់ស្រាលៗក្បែរត្រចៀកដូចជាសំឡេងបំពេនាងអោយកាន់តែទន់ត្របកភ្នែកទៅៗ។ មាត់នាងមិនមានលទ្ធភាពហើបឆ្លើយតបនឹងនាយទេ។ តែសតិបញ្ញានាងនៅមិនទាន់រងឥទ្ធិពលថ្នាំសណ្តំធ្ងន់ធ្ងរដូចកាយខាងក្រៅនៅឡើយ។

សំឡេងមួយខ្សឹបប្រាប់នាងតិចៗថា "ឯងចប់ហើយកេតឪម៉ា! ថ្នាំងងុយមួយដបដែលបងKenអោយនោះ ឯងលេបវាខ្លួនឯងហើយ!"។

នាងបិទត្របកភ្នែកហើយទម្លាក់ខ្លួនទន់ល្វៀងទៅតាមអំណាចថ្នាំសណ្តំ។ នៅពេលដែលកំពុងបណ្តោយខ្លួនអោយទទួលយកស្ថានភាពរលំទាំងជំហរនាងដឹងថាមានហត្ថាដ៏មាំរបស់បុរសម្នាក់ដែលនៅក្បែរបង្អើយរងត្រកងមិនឲ្យនាងបោកផ្ទប់ទៅនឹងក្តារចាប់ពីពេលនោះទៅនាងលែងដឹងអ្វីទាំងអស់។

រាមនរិន្ទសម្លឹងវង្សភក្ត្រសស្លាំងនៃនារីបង្ហាញម៉ូតដែលកំពុងស្ថិតក្នុងរង្វង់ដៃ។ អ្នកប្រែទឹកមុខដៀងភ្នែកទៅរកកែវទឹករបស់ខ្លួនដែលទើបត្រូវបានស្រស់ស្រីលើកយកទៅក្រេបអម្បាញ់មិញ។ ទោះល្ងង់យ៉ាងណាក៏អ្នកប្រុសដឹងថា នារីនេះកំពុងត្រូវថ្នាំសណ្តំប្រាកដណាស់។

គេក្រោកឈរនាំយកទាំងកាយល្វន់ល្វៃរបស់នារីទៅជាមួយពេញក្នុងរង្វង់ដៃ។

ក្រោមផ្សែងអ័ព្ទត្រជាក់ នាយរឿនដែលឈរឆ្លេឆ្លាដូចមាន់រកពងនៅខាងក្រៅបរិវេណសួនម្ចិះស្ទុះសំដៅមក កាលបើក្រឡេកឃើញរាងកាយខ្ពស់សង្ហា កំពុងត្រកងធីតាគួសន្ទនាបោះជំហានមួយៗចេញមក។ គេដើររលះរលាំងមកក្បែរនាយចៅហ្វាយ៖

-នាងកើតអីអ្នកប្រុស?

រាមនរិន្ទមិនឆ្លើយគេប្រញាប់ប្រញាល់ដើររ៉ុយ តម្រង់បន្ទប់សម្រាកមានទាំងមនុស្សជំនិតស្ទុះស្ទាទៅតាមពីក្រោយ។

ដាក់នារីរូបល្អទៅលើគ្រែរួចកាលណា គេងាកមករកមនុស្សក្រោមបង្គាប់ដែលកំពុងអើតកមើលមកពីចម្ងាយដោយទឹកមុខអន្ទះសា៖

-រឿន! នៅឆ្លេឆ្លាក្រៅសួនមានការអីចង់និយាយអ្ហែះ?

រឿនរកហើបមាត់តែគេទច់វិញពេលក្រឡេកទៅឃើញកេតឱម៉ានៅបិទភ្នែកស្ងៀមឈឹងលើគ្រែ។ គេយកម្រាមដៃចង្អុលនាងជាសញ្ញាថាវត្តមាននាងមិនអាចអោយគេនិយាយអ្វីបានឡើយតែរាមនរិន្ទនិយាយកាត់៖

នាងសន្លប់ហើយ! មានរឿងអីឆាប់និយាយទៅ?

នាយរឿនហាក់ទុកចិត្តជាងមុនកាលបើលឺពាក្យបញ្ជាក់របស់រាមនរិន្ទទោះបីគេមិនថ្លើមធំដល់ថ្នាក់ឈានមកជិតគ្រែដំណេករបស់ចៅហ្វាយតែគេបានស្ទុះចូលមកថែមប៉ុន្មានជំហានទៀតប៉ុន្តែគេនិយាយតិចៗល្មមតែឮបានពីរនាក់នាបន្ទប់ធំល្វឹង៖

-អ្នកប្រុស! គ្នាយើងទើបតែបានដំណឹងថា ឥន្ទប្បដិមា នរាធិបតិន្ទត្រូវ ដាក់ដេញថ្លៃនៅអាទិត្យក្រោយនេះហើយ!

អ្នកប្រុសខ្ពស់សង្ហាដែលកំពុងឱនលើកផាហ៊ុមគ្របកាយអោយនារីបង្ហាញម៉ូតទច់ចលនា។ សន្សឹមៗគេងាកមុខមករកមនុស្សក្រោមបង្គាប់បញ្ជាក់ថាសេចក្តីរាយការណ៍ចុងក្រោយកំពុងធ្វើអោយគេភ្ញាក់ផ្អើល។

ជាមួយពន្លឺកែវភ្នែកដែលប្រែទៅជាមុតថ្លាក្នុងន័យសញ្ជឹងគិតគេមិនទាន់វាចាថាយ៉ាងណាទៀតផង នាយរឿននិយាយបន្ថែមភ្លាម៖

-សំបុត្រយន្តហោះពីបាលីទៅJayapura (ក្រុងធំរបស់ខេត្តPapua) មានតែមួយជើងគត់ក្នុងរវាង១សប្តាហ៍គឺចេញនៅយប់ខានស្អែក! យើងត្រូវប្រើពេល១យប់មួយថ្ងៃទើបដល់! ចំណែករបស់នោះនៅ ក្នុងដៃមេកុលសម្ព័ន្ធម្នាក់ ដែលរស់នៅចម្ងាយជាង៣០០គីឡូម៉ែត្រពីក្រុង Jayapura ទៀតប៉ុន្តែរបស់នោះនឹងត្រូវគេនាំយកមកដេញថ្លៃនៅJayapura ។

រាមនរិន្ទដណ្តប់ផាហ៊ុមទៅលើកាយនារីវាងរាវរួចទើបបែរក្រោយដើរមួយៗមករកមនុស្សជំនិតដែលកំពុងឈររង់ចាំបញ្ជានៅចម្ងាយប្រមាណ៦ ឬ៧ម៉ែត្រពីគ្រែ។

បុរសអភិជនបន្លឺឡើងមួយៗ៖

រឿន! របស់នោះមិនអាចដាក់អោយដេញថ្លៃបានទេ! យើងអាចយកលុយប៉ុន្មានទៅដេញក៏បាន តែសំខាន់ បើមានមនុស្សដឹងពីវាច្រើនវាកាន់តែជាគ្រោះថ្នាក់សម្រាប់យើង!

នាយរឿនងក់ក្បាលផ្ទក់ៗរបៀបយល់ការ។ រាមនរិន្ទនិយាយបន្ត៖

-បើមនុស្សយើងនៅPapuaអាចទុកចិត្តបានទេ? ធ្វើយ៉ាងណាពន្យារពេលកុំឲ្យរបស់នោះបានមកដល់ទីក្រុង! ឬមួយពន្យារពេលដេញថ្លៃសិន! ខ្ញុំចង់អោយគ្រប់គ្នាគិតថាឥន្ទប្បដិមានរាធិបតិន្ទ គ្រាន់តែជាពាក្យចចាមអារ៉ាមនឹងគ្មាននៅលើលោកនេះទៀតទេ។

នាយរឿនឱនក្បាលទទួលបញ្ជាល្មមពេលរាមនរិន្ទនិយាយបន្ថែម៖

មួយទៀតរឿន! រៀបចំទៅPapuaយប់ខានស្អែកកុំអោយខកអោយសោះយើងគ្មានពេលទៀតទេ!

រឿននិយាយហាក់ស្ទាក់ស្ទើរ៖

អ្នកប្រុសអាចរង់ចាំដំណឹងនៅទីនេះ ខ្ញុំនាំគ្នាយើងទៅមុនសិនបានទេទាន?

រាមនរិន្ទចងចិញ្ចើម នាយរឿនប្រញាប់ពន្យល់ភ្លាម៖

-ព័ត៌មានប្រាប់មកថា មនុស្សនៅទីនោះមានច្រើនបក្សច្រើនពួក! ស្ថានភាពចេញពីក្រុង Jayapuraទៅកាន់កោះផ្សេងៗគឺផ្សងនឹងគ្រោះថ្នាក់ ស្រុក ឬកោះខ្លះចម្ងាយ៣០ឬ៤០គីឡូម៉ែត្រ ចំណាយពេលដល់ទៅ៣បួនថ្ងៃ ខ្ញុំមិនចង់អោយអ្នកប្រុសរងទុក្ខទេ។ ឬមួយខ្ញុំសុំមនុស្សពីភ្នំពេញមកថែមនិង...

រាមនរិន្ទលើកដៃជាសញ្ញាអោយឈប់រួចពោលបញ្ជាក់ជាចុងក្រោយ៖

-ទៅរៀបចំទៅ! យប់ខានស្អែកខ្ញុំចេញដំណើរគ្មានអីផ្លាស់ប្តូរទេ!

នាយរឿនយល់ហើយថា គ្មានអ្វីអាចកាត់ផ្តាច់ឬរារាំងថៅហ្វាយខ្លួនពី ឥន្ទប្បដិមា នរាធិបតិន្ទ បាននោះទេ ទោះបីកន្លែងនោះគ្រោះថ្នាក់ ឬប្រឈមមុខកម្រិតណាក៏ដោយ។ គេអោនកាយបម្រុងចាកចេញតែក្រឡេកទៅប្រទះឃើញនារីដែលគេងស្តូកស្តឹងលើគ្រែ គេផ្តោតភ្នែកទៅរកនាងសាជាថ្មី។ក្នុងនាមជាអ្នកឃើញ្ញាលដ៏ចំណាប់ចំពោះនាយថៅហ្វាយគេមិនអាចចាកចេញទាំងនៅមន្ទិលទេគេសួរវិញភ្លាម៖

-អ្នកប្រុស? នាង....?

រាមនរិន្ទងាកទៅស្រស់ទងវងដែលនៅស្ងៀមដូចមនុស្សគ្មានវិញ្ញាណលើគ្រែ។ គេសើចចុងមាត់ឆ្លើយទៅកាន់មនុស្សជំនិត៖

-ប្រហែលចង់ធ្វើបាបខ្ញុំ តែវ័ណ្ឌកខ្លួនឯង!

នាយរឿនបើកភ្នែកធំៗ៖

នាងចង់ដាក់ថ្នាំសណ្តំអ្នកប្រុសមែនទេ?

ឃើញមនុស្សជំនិតហាក់ភ្ញាក់ផ្អើលខ្លាំង រាមនរិន្ទមិចភ្នែកលួងរម្ងាប់អារម្មណ៍គេវិញ៖

គ្មានអីធំដុំទេរឿន! នាងប្រហែលជាខ្លាចខ្ញុំពេកតែប៉ុណ្ណឹង! ស្រីនេះល្ងង់ណាស់!

**ភាគទី១១**

ទោះបីថៅហ្វាយនាយវាយតម្លៃហេតុការណ៍ដូចជាផុយៗមែនតែនាយរឿនមិនងាយទុកចិត្តទេ។ គេប្រញាប់បដិសេធការសន្និដ្ឋាននេះ៖

-ខ្ញុំថាមិនមែនប៉ុណ្ណឹងទេ! នាងអាចមានល្បិចផ្សេងទាន!

រឿនប្រហែលជាភ្លេចគិតហើយថាសម្រាប់រាមនរិន្ទ មនុស្សស្រីគ្រាន់តែជួបនិយាយគ្នាបានម្តងអ្នកប្រុសអាចសម្គាល់ដឹងថានាងជាមនុស្សគ្រោះថ្នាក់ ឬអត់ទៅហើយ។

ពេលអ្នកប្រុសដើរសំដៅទៅទូសំលៀកបំពាក់រករៀបចំខ្លួនចូលសម្រាកនាយរឿននិយាយបន្ថែមៈ

-បញ្ជូននាងចេញឲ្យឆ្ងាយពីអ្នកប្រុសកាន់តែល្អទាន!

រាមនរិន្ទដកដង្ហើមធំទាំងអស់សំណើច។ គេដើរមករកមនុស្សដែលជានិច្ចជាកាលទុកសុវត្ថិភាពគេជាចម្បងនោះរួចដើរមកទះស្មាគេ។ អ្នកនិយាយមួយៗៈ

-គ្នាគ្រាន់តែជាមនុស្សស្រីម្នាក់ទេរឿន! កុំធ្វើចិត្តរឹងពេកមើល៍!

នាយរឿនក្រឡេកឃើញស្នាមញញឹមលើបបូរមាត់ថៅហ្វាយកំលោះគេហាក់គ្មាន់ក្នាញ់ថាមនុស្សលើមនុស្សដូចរាមនរិន្ទនៅតែឆ្លងមិនរួចពីសម្រស់ស្រីស្អាត តែគេមិនហ៊ានតមាត់ ថាយ៉ាងណាទៀតទេមានតែឈ្ងោកមុខទាំងមិនអស់ចិត្ត។ រាមនរិន្ទស្វាបបណ្ដេញកងការពារជំនិតរូបនេះ ធ្វើឲ្យនាយរឿនត្រូវចាកចេញចោលថៅហ្វាយនាយស្រស់សង្ហាទាំងពាំនាំទៅជាមួយនូវពិភាល់។

មុនចាកចេញគេដៀងភ្នែកទៅរកនារីរូបស្អាតដែលកំពុងផ្ញើប្រាណក្នុងក្រញាំដៃបុរសអភិជន។ នាយរឿនសច្ចាក្នុងចិត្តៈ

-បើនាងធ្វើអ្វីលោកប្រុសយើង! នាងហែកដីរត់ដល់ណាក៏យើងតាមរកទាល់តែឃើញដែរកេតឪម៉ា!

មនុស្សក្រោមបង្គាប់ចេញផុតល្មមពេលបុរសមានអំណាចបញ្ចប់ការប្ដូរសំលៀកបំពាក់របស់ខ្លួន។

គេចាប់លើកទូរស័ព្ទដៃដើរសំដៅរានហាលខាងមុខហើយសន្ទនាទៅកាន់ប្រទេសកម្ពុជាជាមួយលោកឪពុក។ នៅក្រោមអ័ព្ទផ្សេងត្រជាក់នារាត្រីកាលនរៈនៅអង្គុយត្រងត្រាប់ស្ដាប់ពាក្យពេចន៍បញ្ជាពីនាយសមុទ្រមកមិនហ៊ានឲ្យថ្លោះធ្លោយមួយម៉ាត់ណាឡើយ។ ក្រសែមុតថ្លារបស់រាមនរិន្ទបញ្ជាក់ជាស្រេចហើយថាការងារនេះជាការងារដ៏ធំមួយដែលមិនអាចឲ្យល្អក់កករជាដាច់ខាតទោះបីយ៉ាងណាក៏ដោយ។

ពេលវេលារំលងទៅ គេដាក់ទូរស័ព្ទបញ្ចប់ការសន្ទនាជាមួយទឹកមុខនឹងថ្កល់ជាសញ្ញាត្រិរិះ។

ទោះបីមុខឈ្មោកទៅរកកម្រាលឥដ្ឋសាងពីថ្មម៉ាបដ៏ប្រណិតតែភ្នែកគេកំពុងរេសម្លឹងមកផ្ទៃវេហាដែលប្រែទៅជាខ្មៅងងឹតដោយសារព្រះចន្ទចាប់យាងចោលនភាល័យ។

អាធ្រាត្រឈានដល់ហើយ។ក្នុងបរិយាកាសស្ងាត់ជ្រងំដែលសត្វលោកនានាកំពុងលង់ក្នុងតម្រេកស្កប់ស្កល់

តើក្នុងបេះដូងបុរសអភិជនមាននារីបង្ហាញម៉ូតគ្មានឋានៈគ្មានតួនាទី ឬមួយក៏មានតែស្រមោល ឥន្ទប្បដិមា នរាធិបតិន្ទដែលគេធ្លាប់តែឮត្រឹមពាក្យចចាមអារ៉ាមតៗគ្នាក្នុងសង្គមខ្មែរ?

គឺគ្មានអ្នកណាដឹងទេ។

បុរសសង្ហាដែលតែងតែនិយាយតិចជាងធ្វើ សើចច្រើនជាងខឹង និងគិតច្រើនជាងបញ្ចេញនោះ ចង់វាស់ស្ទង់ឲ្យដល់ជម្រៅចិត្តគេ ប្រហែលពិបាកជាងវាស់ជម្រៅសមុទ្រទៅទៀត។

គេបែរខ្លួនត្រឡប់ចូលក្នុងបន្ទប់សម្រាកវិញនៅពេលភាពហត់នឿយគ្របដណ្ដប់លើរាងកាយ។នរៈឈានទៅចាក់ទឹកនៅកូនBarក្នុងបន្ទប់ខ្លួនក្រេបក្អឹកដូចទម្លាប់រាល់ដងមុនចូលនិទ្រាប៉ុន្តែដំណក់ទឹកត្រជាក់ស្រេងបានដាស់នាយឲ្យនឹកឃើញដល់នារីរូបល្អដែលកំពុងលង់លក់នៅលើគ្រែ។ គេលើកកែវមកមើលហើយញញឹមចុងមាត់។

"នាងចង់លេងផ្លូវហ្នឹងជាមួយខ្ញុំផងកេតឌីម៉ា? "នរៈសង្ហានឹកក្នុងចិត្តស្ងាត់ៗមុនពេលងាកទៅសម្លឹងមើលនារីដែលគេងលក់ភ្លឹងលើគ្រែ។ គេដាក់កែវចុះរួចបោះជំហានធ្ងន់ៗសំដៅទៅទីនោះ។ ពីក្រោម រស្មីពណ៌មាសនៃអំពូលចរណៃ ធីតាប្រមុខកិន្នរីហ្វេស្សិនបិទភ្នែកលង់លក់ស្ងៀមឈឹង បន្សល់នូវទឹកមុខស្លូតស្ងប់ និងបបូរមាត់ពណ៌ឈូកស្លេក។

"មកជួបមនុស្សដែលធ្លាប់ជួយសង្គ្រោះខ្លួន គ្រាន់តែតុបតែងខ្លួនបន្តិចក៏គ្មាន នាងគ្មានការគោរពការណាត់ជួបអីបន្តិចសោះ "រាមនរិន្ទនឹកគិតម្នាក់ឯងសាជាថ្មី។កែវភ្នែកគេរេសំដៅគល់ក និងសាច់ស្មាដែលប្រែទៅជាពណ៌មាសខ្ចីឆ្លុះជាមួយកម្រាលពូករលើបរលោង។ មកដល់ត្រង់ណេះហើយបើមិនសម្លឹងទៅរកដើមទ្រូងនាង ប្រាកដជាមិនមែនមនុស្សប្រុសពេញលក្ខណៈឡើយ។

សម្រស់ក្នុងភាពជានារីរបស់កេតឌីម៉ាអណ្ដែតមកកំដរកែវភ្នែកនរៈម្ចាស់បន្ទប់។ ទោះមិនចាំចាប់តុបតែងក៏ពេលនេះនាងនៅតែអាចបង្កាត់ភ្លើងចិត្តនាយឲ្យមួហ្មងចង់ត្រើតក្នាញ់ដោយឯកឯងដែរ។

នៅចំពោះមុខស្រីស្អាត និងស្ថិតនៅក្នុងបរិយាកាសស្ងប់ស្ងាត់គួរព្រឺព្រួច វិចារណញ្ញាណ និងកំសួលតណ្ហាពិតជាមិនអាចដើរទន្ទឹមគ្នាបានឡើយ ជាហេតុធ្វើឲ្យហត្ថរបស់បុរសរូបល្អលូកទៅទាញផាហ៊ុមរបូតចេញពីខ្លួនប្រាណស្រីស្រស់ដោយមិនដឹងខ្លួន។

គេដាក់បបូរមាត់ជាដំបូងទៅរកគល់កដែលម្ចាស់វាគ្មានសមត្ថភាពតបត ហើយស្រវាឱបរាងកាយទន់ល្វតដូចល្វាចេកទៅក្នុងរង្វង់ដៃ។ ក្លិនខ្លួនតរុណីនាំត្រឡប់មកវិញនូវអនុស្សាវរីយ៍នារាត្រីផ្អែមល្ហែមកាលពីជាងបីខែមុន ជារាត្រីដែលរាមនរិន្ទបានរស់សុខសាន្តក្រោមដំណក់ទឹកភ្នែករបស់នាង។ សម្ដីនាយBirdជាមនុស្សជំនិតលាន់មករសឹបក្នុងសោតាទាំងទ្វេ៖

"ស្រីបង្ហាញម៉ូតនោះគឺអត់ដឹងរឿងតែម្ដង! យាយនោះបោកប្រាស់ទាំងសងខាងហើយនាំនាងមកកំដរអ្នកប្រុសដូរជាមួយលុយជំពាក់ បន្ទាប់មកប្រាប់អ្នកប្រុសថា នាងស្រលាញ់ចង់សងគុណហើយអ្នកប្រុសក៏ចាយលុយទៅទំនុកបម្រុងរាល់ខែ! តែនាងមិនដែលទទួលលុយទេព្រោះនាងគិតថាទូទាត់គ្នាចប់ហើយ!"

រាមនរិន្ទលែងដៃពីប្រាណនារីរូបល្អនិម្មិតនឹកឃើញដល់ពាក្យចុងក្រោយរបស់នាយBird។ គេដកនាសាចេញពីរាងកាយល្វតល្ហៃហើយងើបមុខសម្លឹងនាង។ទឹកមុខក្រៀមក្រំដែលនៅសេសសល់បង្ហាញនាយជាស្រេចហើយថា ការមកកាន់ Amandariមិនមែនជាបំណងរបស់នាងដាច់ខាត។

"សូម្បីតែបានរាត្រីទីមួយរបស់នាងហើយ ក៏នាងអត់មានមនោសញ្ចេតនាឲ្យយើងដែរកេតឌីម៉ា?"

អ្នកដឹងហើយថានាងមកកាន់ទីនេះព្រោះបាក់ស្បាតពីរឿងអ្នកស្រីកុលាបត្រូវបានក្រុមកងការពារវាយដំ។ ប្រសិនបើយប់នេះនាងមិនព្រមមកទេ នាងខ្លាចថាស្ត្រីនោះអាចនឹងត្រូវសើរើរឿងច្រើនដែលពាក់ព័ន្ធដល់ការជួញដូរមនុស្សរបស់គាត់រហូតដល់ពេលនេះនាងដឹងការពិតពីកលល្បិចរបស់គាត់ហើយតែនាងស្មានថារាមនរិន្ទនៅមិនទាន់ដឹងអ្វីនៅឡើយម្ល៉ោះហើយនាងនៅតែព្យាយាមជួយបិទបាំងគាត់។

"នាងជួយគេបានដល់អង្កាល់? ថ្នាំសណ្ដំជួយនាងបានមួយយប់នេះ ចុះនៅយប់ផ្សេងៗទៀតស្រីល្ងង់?"

ការលេងល្បែងស្នេហាជាមួយមនុស្សគ្មានស្មារតីជារឿងផ្ទុយស្រលះ និងអត្តចរិតកូនប្រុស ហើយការបង្ខំរួមរស់ជាមួយនារីដែលគ្មានមនោសញ្ចេតនាឲ្យខ្លួនរឹតតែឆ្ងាយពីសារជាតិរាមនរិន្ទទៅទៀត។

នរៈសង្ហាក្រោកចេញពីនាង បណ្ដោយឲ្យនារីរូបស្អាតនៅលង់លក់សុខសាន្តតែម្នាក់ឯងក្រោមឥទ្ធិពលនៃថ្នាំគីមី។

## វគ្គទី៦

## មិត្តទ្រូសមិត្ត ម្ចាស់ចិត្តក្លែងក្លាយ

ដោយសារសីលធម៌របស់បុរសមកពីគ្រួសារអ្នកនយោបាយ កេតឌីម៉ាអាចឆ្លងផុតរាត្រីនៅ Amandariដោយសុវត្ថិភាព ប៉ុន្តែនាងមិនដឹងឡើយថា បុរសម្នាក់ទៀតដែលនាងកំពុងស្រលាញ់ផ្តល់ភាពភក្តីពេញបេះដូងកំពុងស្ថិតនៅក្នុងរាត្រីដ៏ស្រើបស្រាលផ្អែមល្ហែមជាមួយនារីផ្សេង។សំខាន់បំផុតគឺនារីនោះគឺជាមនុស្សដែលនាងបានទុកចិត្តទុកថ្លើមជាយូរមកហើយ។

នៅក្នុងបន្ទប់ផ្សេងមួយចម្ងាយប្រមាណ២គីឡូម៉ែត្រពីAmandari សុភាពបុរសអភិជនក្នុងស្រោមកំពុងក្រសោបរាងកាយនារីបង្ហាញម៉ូតឈ្មោះលំអងពេញរង្វង់ដៃដោយសេចក្ដីស្នេហា។ប្រុសស្រីទាំងពីរបានជាន់ពន្លិចមនោសញ្ចេតនានឹងទំនុកចិត្តរបស់ធីតាកម្សត់កេតឌីម៉ាជាមួយនឹងផែនការប្រើប្រាស់នាងជាបង្អោងឆ្ពោះទៅវាយប្រហាររាមនរិន្ទពីទីងងឹត។ ក្រៅពីមិត្តទ្រូសមិត្ត និងម្ចាស់ចិត្តក្លែងក្លាយទាំងទ្វេ នាយBirdមនុស្សក្រោមបង្គាប់របស់ រាមនរិន្ទក៏កំពុងស្ថិតនៅក្នុងចំណោមនោះដែរ។

Kenបង្ហាញទឹកមុខមួម៉ៅបន្ទាប់ពីស្ដាប់ចប់សេចក្ដីរាយការណ៍របស់នាយBird។ គេនិយាយឡើងទាំងសោះកក្រោះ៖

- ស្អីគេ?ស្រីពត្លើហ្នឹង វាច្រឡំលេបថ្នាំខ្លួនឯងអ្វីអាBird?

ឃើញកែវភ្នែកមុតថ្លាទាំងគូររបស់Ken សម្លឹងទៅរកនាយBirdហាក់គ្រេវក្រោធ លំអងដែលកំពុងអង្គុយជំទាស់ក្រចក ក្នុងរង្វង់ដៃប្រុសស្នេហ៍រលាស់ដៃនាយចេញ រួចនិយាយបញ្ចិតបញ្ចៀងហាក់គ្នាន់ក្នាញ់៖

-ព្ធអញ្ចឹង ប្រហែលបងKenកើតក្តៅចិត្ត ដោយសារស្រីសំណព្វធ្លាក់ក្នុងដៃប្រុសស្អាតកូនតំណាងរាស្ត្រមែនទេ?

នាយKenដឹងថាគូកំណាន់កំពុងកើតរោគច្រណែនប្រច័ណ្ឌប៉ុន្តែនាយមិនត្រឹមតែមិនលួងលោមនាងទេថែមទាំងឌឺដងត្រឡប់វិញ៖

កុំមកថាឲ្យបង! ក្រែងខ្លួនឯងទេដឹង? ហៅអ្នកណាប្រុសស្អាត?បើអាកូនអ្នកនយោបាយនោះវាស្អាតណាស់ ចូលខ្លួនទៅជំនួសកេតឌីម៉ាតែម្តងទៅអញ្ចឹង!

ដឹងថាគូស្នេហ៍ទាំងពីរកំពុងឌឺគ្នាកណ្តាលបរិយាកាសតានតឹង នាយBirdនិយាយកាត់ភ្លាម៖

-បងKenកេតឌីម៉ាតាមមើលយប់មិញអត់បានអីៗជាមួយរាមនរិន្ទទេ!

Kenងាកមករកមនុស្សដែលខ្លួនបានបញ្ជូនទៅជារនុកក្នុង។គេសើចញាក់ស្មាបែបហួសចិត្តមុននឹងនិយាយសន្ធាប់៖

-ស្អីទៀតហើយអ្ហ៎ា? មនុស្សស្រីដេកស្មៀមក្នុងបន្ទប់ជាមួយវាពីរនាក់តទល់វាទុកនៅឲ្យសោយរាជ្យដែរអាBird? អ្ហែងទុកទៅនិយាយឲ្យក្មេងថ្នាក់ទី៣ស្តាប់ទៅអ្ហ៎ា!

នាយBirdស្ទុះចូលមកជិតចៅហ្វាយសម្បូរល្បិចបន្ទាប់ពីលំអងធ្វើមុខស្មើក្រោកចេញពីសាឡុងទៅរកតុភេសជ្ជៈ។ នាយBirdខ្សឹបតិចៗដាក់ត្រចៀកនាយចៅហ្វាយ៖

គេតាមដានជាប់! គឺរាមនរិន្ទចេញទៅរានហាលនិយាយទូរស័ព្ទដល់ម៉ោង១១កន្លះ។ហើយព្រឹកឡើងគេចូលទៅឃើញសល់ភួយខ្មើយលើសាឡុង។ Tableរាមនរិន្ទក៏នៅហ្នឹងដែរ មនុស្សនេះទម្លាប់ធ្វើការមួយយប់ទល់ភ្លឺ។ និយាយរួមយប់មិញអត់មានបានការអីទេបង!

លំអងដៃចាក់ស្រាក្រេបបណ្តើរ មាត់និយាយឌឺគូស្នេហ៍បណ្តើរ៖

-ធូរចិត្តហើយឬនៅ? ស្រីស្អាតរបស់បងឯងមិនទាន់ខាតបង់អីទេ!

Kenគំហកវិញទាំងទឹកមុខមាំ៖

វាអត់សំខាន់ទេ! ខាតអីក៏ខាតទៅ សំខាន់យើងត្រូវការបានព័ត៌មានឆាប់ថា រាមនរិន្ទមកបាលីធ្វើអី?ហើយម៉េចក៏មិនទាន់ត្រឡប់ទៅវិញ? ចំណែកស្រីអត់បានការនោះដេកដូចស្លាប់មួយយប់ទល់ភ្លឺ ធ្វើម៉េចយើងបានតម្រុយអីទៅ? ឆ្កួតមែន!

ហាក់នឹកឃើញបន្ថែម គេងាកមកសម្លុតនាយBird៖

-ចុះឯងអាBird? ទៅនៅជាមួយរាមនរិន្ទរាប់ខែ ឯងបានតែប៉ុណ្ណឹងមករាយការណ៍?ឯងអត់ដឹងអីខ្លះទេ? ថាពួកនោះពពាក់ពពូនមកបាលីធ្វើអី?

នាយBirdឆ្លើយតបដោយអេះអុញ៖

-ពេលមានរឿងសំខាន់គេមិនដែលនិយាយអីនៅមុខខ្ញុំផង ព្រោះខ្ញុំទើបចូលថ្មី!ចំណែកអាមួយឈ្មោះរឿននោះវាតាមក្រុងមេវាដល់ហើយបង! សូម្បីតែកេតឌីម៉ា វាមិនចង់ឲ្យចៅហ្វាយវាពាក់ព័ន្ធប៉ុន្មានទេ វាហាមរហូត តែរាមនរិន្ទចេះតែមិនដាច់ចិត្ត។ កាលហ្នឹងកុំតែខ្ញុំខំលើកយករឿងល្បិចយាយកុលាបមកបកអាក្រាតឲ្យរាមនរិន្ទដឹងដើម្បីឲ្យខឹងសម្បា កុំអីគេក៏មិនបានខ្វល់ទៅណាត់កេតឌីម៉ាឲ្យជួបនៅ Amandariដែរ! ដែលរាមនរិន្ទណាត់ឌីម៉ាព្រោះចង់មើលថានាងនៅធ្វើពីជួយយាយកុលាបរបៀបណាខ្លួនប៉ុណ្ណឹងទេ!

លំអងលើកកែវស្រាមកហុចឲ្យនាយKen។ កំលោះអភិជនសម្បូរល្បិចលើកមកក្រេបក្អឹករួចទើបនិយាយដោយទឹកមុខស្មើ៖

ទោះបានណាត់ជួបក៏ដោយ ផែនការរលាយបាត់ហើយ! ស្រីល្ងង់ហ្នឹងភ្លាត់ស្មៀតដេកលក់ខ្លួនឯងពេញមួយយប់ មានបានការអីទៅ? ស្អីក៏មិនបានដឹងមិនបានឮ! ខាតពេលទទេ!

លំអងមកដាក់បង្គុយជិតពាណិជ្ជករដែកថែបKenសាជាថ្មីដោយកាយវិការម្ញិកម្ញ៉ក់។ នាងនិយាយបណ្ដើរលើកកែវក្រេបបណ្ដើរ៖

-មិនប្រាកដទេ! ទោះយប់មិញអត់បានការអីក៏នៅមានយប់ផ្សេងទៀតដែរ! សំខាន់យើងត្រូវដឹងថា ហេតុអីរាមនរិន្ទលើកលែងឲ្យកេតឌីម៉ា? គេលង់ស្នេហ៍វាមែនហើយដឹង?

Kenមមីភ្នែករិះគិត។ ពិតមែនហើយ ហេតុអ្វីដឹងរឿងនាងចង់ចាក់ថ្នាំសណ្ដំហើយ រាមនរិន្ទនៅតែមិនរករឿងនាង? គេដៀងភ្នែកមកលំអង។ ភ្លាមនោះនាយBirdបញ្ចេញយោបល់៖

-ប្រហែលជារាមនរិន្ទគិតថា កេតឌីម៉ា ធ្វើហ្នឹងដោយសារចង់ការពារយាយកុលាប! ដល់ពេលដឹងថានាងចង់ដាក់ថ្នាំខ្លួន គេអាចគិតថានាងមិនចង់នៅជាមួយគេ គេក៏មិនចង់បង្ខំចិត្តនាងនោះ!

Kenពេបមាត់៖

-ឯងកុំមកចង់ផ្សព្វផ្សាយថាវាជាមនុស្សល្អណាអា Bird!

នាយBirdដកថយវិញ ហើយជ្រប់មុខនៅស្ងៀម។ នៅតែលំអងទេដែលគិតបណ្ដើរនិយាយបណ្ដើរ៖

-ប្រុសពូកែយ៉ាងណាក៏នៅឆ្លងមិនផុតទឹកភ្នែកស្រីស្អាតដែរ! ជួនកាលរាមនរិន្ទឃើញអញ្ចឹងទៅជាអាណិតកេតឌីម៉ា! បើអញ្ចឹងមែន យើងនៅមានក្រឡាហក់ទៀត! កេតឌីម៉ានៅតែជាកូនអុកសំខាន់របស់យើងដដែលទេបងKen!

Kenងាកមុខចេញ គេនិយាយទាំងលូកដៃចុចបញ្ជាទូរទស្សន៍បើកដោយមួហ្មង៖

-បានការអីទៅ? កេតឌីម៉ាត្រូវទៅភ្នំពេញវិញល្ងាចនេះហើយ!

លំអងព្រិចភ្នែកត្រិះរិះ។ នាងងក់ក្បាលផ្ញក់ៗ មាត់និយាយរអ៊ូៗ៖

-ការងារយើងមិនទាន់ចប់ គ្មានរឿងអីត្រូវឲ្យនាងច្រម៉ក់ហ្នឹងទៅវិញស្រួលៗទេ!

នាយBirdនិងអភិជនKenងាកមកសម្លឹងមុខនារីមានល្បិចហាក់រង់ចាំស្ដាប់កលកិច្ចថ្មីដែលនាងទើបតែរកនឹកឃើញ។ លំអងនិយាយបន្តតិចៗ៖

-បងKenបងត្រូវរកវិធីលួងលោមស្រីសំណព្វចិត្តបងឲ្យហើយទៅ ឲ្យវាទៅនៅជាមួយរាមនរិន្ទទៀតរហូតដល់ខាងប្រុសទន់ចិត្ត ខាងស្រីអាចយកការណ៍បានមកឲ្យយើង! ចំណែកខ្ញុំត្រូវធ្វើម៉េចឲ្យបកេតឌីម៉ាលុបចោលគម្រោងការត្រឡប់ទៅភ្នំពេញវិញល្ងាចនេះ!

នាយBirdញញឹមខ្ទឹបទទួលបទបញ្ជាម្ចាស់ស្រីវៃឆ្លាតខាងល្បិចទុច្ចរិត។ ចំណែកអភិជនក្បត់ស្នេហ៍សើចចុងមាត់ទទួលយកផែនការថ្មីរបស់នារីកំណាន់។ ភ្លាមនោះលំអងពោលបន្ថែម៖

Bird! ការងារឯងនៅខាងណោះគឺត្រូវចាក់ដោតធ្វើម៉េចឲ្យរាមនរិន្ទកាន់តែអាណិតស្រលាញ់កេតឌីម៉ា។ ឯងត្រូវបន្ថែមឱកាសឲ្យអង្គរក្លាយជាបាយ ហើយនៅពេលត្រីព្រមស៊ីសន្ទូច ត្រីដ៏

ធំនេះនឹងបានមកលើយើង! ចំណីចំណុកដែលវាខំសន្សំកម្លាំងធ្វើមក នឹងក្លាយជារបស់យើងទាំងអស់!

នាយBirdឱនក្បាលត្រង់ត្រាប់បញ្ជា៖

-បាទអ្នកនាង!

នាយBirdចាកចេញទៅ។ អភិជនKenដែលចង់ឈ្នះកំលោះគ្រួសារអ្នកនយោបាយដោយផ្លូវកាត់ងាកមកសងគុណនារីកំណាន់ដោយស្នាមថើបមួយខ្សឺតជាសញ្ញាសរសើរថាអ្នកពេញចិត្តចំពោះភាពឆ្លាតវៃរបស់នាងណាស់។ បានដូច្នេះនារីរូបស្រស់ទ្រុស្តមិត្តនិយាយដៀមដាមភ្លាម៖

-ហ្នឹងប្រាកដហើយថាប្រគល់កេតឌីម៉ាសង្សារសំណព្វចិត្តឲ្យទៅរាមនរិន្ទ អត់ស្តាយស្រណោះនោះបងKen?

នាយKenសើចបង្ហាញថ្ពាល់ខួចស្រស់សង្ហា៖

បងមិនចេះស្រលាញ់មនុស្សស្រីល្ងង់ទេ! ពេញចិត្តតែស្រីឆ្លាតដូចលំអងអញ្ចឹង បានអាចចូលមកជាម្ចាស់បេះដូងបងបាន!

នារីក្បត់មិត្តក្តាប់មាត់សើចបញ្ចេញភាពអំនួតតាមរយៈពន្លឺភ្នែក។ នាងគិតម្នាក់ឯងស្ងាត់ៗក្នុងចិត្ត៖

កេតឌីម៉ា! ឯងច្រឡំហើយដែលគិតថាខ្លួនឯងលេខមួយនោះ!

នាងលើកទូរស័ព្ទក្រោកដើរចេញពីកំលោះ Kenខ្លាចថាអ្នកម្ខាងទៀតដែលត្រូវលើកទូរស័ព្ទស្តាប់ឮសំឡេងនាយដោយប្រការណាមួយ។

------

ថតសំឡេងទូរស័ព្ទរោទ៍លាន់ឡើងកាត់ផ្តាច់ដំណេកដ៏សុខសាន្តជិតដប់ម៉ោងរបស់អ្នកគ្រូបង្ហាញម៉ូត។ កេតឌីម៉ាបើកភ្នែកសន្សឹមៗទទួលយកពន្លឺស្រាលៗស្រទន់នៃអំពូលដំណេកពណ៌លឿងស្រាល។ នាងរេភ្នែកសម្លឹងជុំវិញខ្លួន រួចបើកភ្នែកធំៗមុនប្រញាប់ច្រត់ដៃយោងខ្លួនក្រោកអង្គុយ។

ក្បាលប្រែទៅជាធ្ងន់ពាប់ហាក់ដូចមិនបានគេង ទោះបីជានាងបានបិទភ្នែកជិតឈឹងតាំងពីម៉ោង១០យប់រហូតដល់ម៉ោង៩ព្រឹកហើយក៏ដោយ។ កេតឌីម៉ាមិនអាចធ្វើអ្វីឲ្យលើសពីលើកដៃទាំងពីរមកឈ្លីថ្ងាសនោះទេ។

**ភាគទី១២**

ស្រស់ស្រីខំបើកភ្នែកព្រឹមៗសាជាថ្មីដើម្បីកំណត់ថាខ្លួនកំពុងនៅទីណា។ ស្លាកAmandari ព្យួររណេងរណោងនៅលើវាំងននចុងជើងបានបង្អើលនាងឲ្យស្រវាំក្រោកសាជាថ្មី។ ស្រមោលភ្លឺពណ៌លឿងទុំដាមមកពីក្រៅតាមរយៈវាំងននមុខបន្ទប់ ហាក់ប្រាប់កេតឌីម៉ាជាស្រេចហើយថាមេឃភ្លឺហើយ។ នារីរូបល្អនាំកាយចាកចោលទីដំណេកបោះជំហានល្វើយៗទៅកាន់រានហាលខាងមុខរួចលូកទាញបើកវាំងននសម្លឹងទៅខាងក្រៅ។

ពន្លឺទិនករនាថ្ងៃថ្មីបានធ្វើឲ្យនាងភើតទ្រូងដោយភិតភ័យលែងរវល់នឹងសំឡេងរោទ៍រន្ថើនរបស់ទូរស័ព្ទ។

"យើងកំពុងនៅAmandariនៅឡើយ? នេះម៉ោងប៉ុន្មានហើយ? ភ្លឺបាត់ហើយហ្នឹង?ម៉េចក៏យើងដេកដល់ថ្នាក់នេះ?"

រង្វង់ដៃអ្នកណាម្នាក់លូកមកក្រសោបចង្កេះរាងស្តួចពីក្រោយជាប់ ធ្វើឲ្យមាណវីភ្ញាក់ក្រញាង ស្វាងចែសពីងោកងុយអស់កម្លាំងរលាស់ដៃដ៏ព្រហើននោះចេញដោយបែរក្រោយជាបន្ទាន់ ។

រូបរាងមាំទាំនៃបុរសម្នាក់ដែលនាងស្គាល់ច្បាស់ហើយដែលបេះដូងតែងលោតខុសចង្វាក់ពេលជួបមុខគេនោះពេលនេះកំពុងបង្ហាញខ្លួននៅក្បែរនាងបង្កើយ...។...

តរុណី ភ្លាត់មាត់តិចៗតាមប្រតិកម្មភ្ញាក់ផ្អើល ៖

លោកប្រុសរាម?

អតិជនម្ចាស់បន្ទប់ដែលកាលពីយប់បានប្រឹងរំលត់ភ្លើងតណ្ហាចោលដោយសារការស្រលាញ់កិត្តិយសជាកូនប្រុសនោះនៅតែរឹងទទឹងលូកដៃមកក្រសោបរាងកាយស្រស់ស្រីសាជាថ្មីអោយខាងតែបាន ហើយមាត់ពោលសួរ ៖

ចុះស្មានថាអ្នកណា ?

ឌីម៉ាព្យាយាមដកកាយចេញពីផែនទ្រូងគេតាមធម្មជាតិនៃនារីក្រមុំរម្យទមហើយញញឹមលុបចោលភាពស្រងូតស្រងាត់ពីផ្ទៃមុខតែនាងក៏ដឹងដែរថា គេគ្មានផ្លូវឲ្យនាងធ្វើតាមចិត្តទេបើមើលលើកម្លាំងដៃគេដែលក្រសោបចង្កេះនាងតឹងយ៉ាងនេះ។

សំឡេងរាមនរិន្ទលាន់មកតិចៗក្បែរត្រចៀកៈ

-ចង់គេចទៅណាទៀតកេតឌីម៉ា?

តរុណីគ្មានវិធីអ្វីក្រៅពីនិយាយបន្លប់មិនឆ្លើយសំនួរៈ

-ខ្ញុំដូចឮសូរទូរស័ព្ទរោទ៍!

រាមនរិន្ទញញឹមចំអក គេនៅតែបន្ថែមរឹតបន្តឹងរាងកាយនាងពីក្រោយដោយដាក់ចង្កាទៅលើស្មានាង។ ទោះបីនរៈនៅស្ងៀមមិនខ្វីផ្ទាញ់ផ្ទាលតែឌីម៉ាយល់ថាគេកំពុងទុកឱកាសឲ្យនាងបកស្រាយរឿងរ៉ាវកាលពីយប់មិញ។ នាងក្រមុំរម្យទមមិនដឹងមានមធ្យោបាយអីក្នុងការស្រោចស្រង់ស្ថានការណ៍មានតែនិយាយលឺបលេ គ្មានចុងគ្មានដើមៈ

-គឺ មិនសមសោះដែល....ដែល...ដែលងងុយគេងដល់ថ្នាក់ហ្នឹង! ខ្វះការគួរសមដល់ហើយ!

នាងសម្លឹងទៅក្នុងកញ្ចក់ចំពោះមុខឃើញនរៈសង្ហានៅតែរក្សាស្នាមញញឹមលើបបូរមាត់គ្មានសញ្ញាថាគេខឹងសម្បារ ឬយ៉ាងណាឡើយ។ នាងមិនបង្អង់ក៏និយាយបន្ថែមៈ

-លោកប្រុសរាម!គឺ...គឺ..សូមទោសផង!

អភិជនវ័យក្មេងផ្ទាញ់ផ្ទាលស្រីស្អាតដោយប្រយោគខ្លីៗៈ

-ចូលចិត្តធ្វើប្លែកៗ ហើយមកសុំទោសតាមក្រោយតែអញ្ចឹង?

កេតឌីម៉ាធ្វើភ្នែកក្រឡេកក្រឡាប់ផ្ទះមិនដឹងពីវិធីឆ្លើយតប។ ភ្លាមនោះនាងឮគេនិយាយបន្ថែម ៖

-ពូកែសូមទោសពេក ឥឡូវគួរដល់ពេលអោយទោសម្តងដែរ!

ភ័យខ្លួនកេតឌីម៉ានិយាយកាត់ភ្លាមៈ

-ជើងយន្តហោះខ្ញុំត្រូវត្រឡប់ទៅវិញម៉ោង៦ល្ងាចនេះហើយ។ សុំទៅរៀបចំខ្លួនសិនបានទេ?

រាមនរិន្ទសួរវិញធ្វើមិនខ្វល់នឹងសភាពប្រញាប់ប្រញាល់របស់នាង៖

-ចុះពន្យារនៅពីរបីថ្ងៃសិនអត់បាន?

ឱម៉ាចាប់ផ្តើមភ័យក្តុកលើសដើម។ ទោះបីគេនិយាយដូចលេងៗតែនាងយល់ថាប្រយោគចុងក្រោយដូចជាការចេញបញ្ជាជាជាងការស្នើសុំ។ នាងរិះរកមធ្យោបាយបដិសេធដោយលំបាក។ គិតហើយគិតទៀតនៅតែមិនដឹងថាត្រូវបដិសេធរបៀបម៉េចសំណាងល្អគឺម្តងណេះសំឡេងទូរស័ព្ទរបស់រាមនរិន្ទរោទ៍ម្តង។

កេតឱម៉ាអរភើត នាងប្រញាប់និយាយតិចៗប្រាប់បុរសដែលកំពុងឱបនាងជាប់មិនរបេះដៃ៖

-លោកប្រុសរាម! មានទូរស័ព្ទ!

រាមនរិន្ទដឹងថាស្រីស្រស់រកតែឱកាសគេចចេញពីគេ ម្ល៉ោះហើយគេមិនចង់លែងនាងដោយងាយៗដូច្នេះទេ ប៉ុន្តែនឹកឃើញដល់បេសកកម្មដ៏សំខាន់ចំពោះមុខ គេចាំបាច់ត្រូវដកចិត្តពីការលេងល្បែងឌឺដងត្រឡប់ចូលមកក្នុងបន្ទប់ហើយលើកទូរស័ព្ទមកនិយាយ។

ពេលបុរសសង្ហាបង្ហើបពាក្យអាឡូភ្លាម ធីតាយើងរួសរាន់ស្ទុះចូលទៅក្នុងបន្ទប់ដែរ ដើម្បីប្រមូលកាបូបស្ពាយខ្លួនដែលត្រូវបានរក្សាទុកអោយលើសាឡុងបន្ទាប់ពីខ្លួនត្រូវបានលង់លក់ក្រោមស្នាដៃខ្លួនឯង។

បានអ្វីៗក្នុងដៃអស់ហើយនាងងាកទៅរករាមនរិន្ទដែលកំពុងនិយាយទូរស័ព្ទតិចៗក្បែរចុងម្ខាង។ឃើញនរៈសម្លឹងមក នាងប្រញាប់លើកដៃសំពះជាសញ្ញាជម្រាបលានាយរួចរួសរាន់ចាកចេញពីបន្ទប់ទាន់ឱកាសហុចឲ្យដោយមិនខ្វល់ថារាមនរិន្ទគិតដូចម្តេចឡើយ។

        មកដល់មាត់បន្ទប់នាងវាក់អើនឹងវត្តមាននាយរឿនកំពុងស្ទុះចូលទៅនាងញញឹមគួរសមគេបន្តិច បុរសអង្គរក្សក៏ញញឹមដាក់នាងដោយបង្ខំ ជាការគួរសមដែលតាមពិតទៅគេមិនចង់ឲ្យមានស្រីណាមកពាក់ព័ន្ធនឹងជីវិតចៅហ្វាយនាយខ្លួនក្នុងកាលៈទេសៈបែបនេះឡើយ។

នៅសួនច្បារខាងក្រៅ នាងជួបនាយBirdមនុស្សបង្កប់ដែលទើបត្រឡប់មកពីជួបអភិជនបញ្ឆោតស្នេហ៍។ នៅចំពោះមុខ ឱម៉ាមិនដឹងទេថាបុរសនោះជាមនុស្សបង្កប់ ដែលKenប្រើ

មកឲ្យនៅក្បែររាមនរិន្ទដែរទេ។ នាងញញឹមដាក់គេបន្តិចរួចដើរហួសទៅព្រោះទោះយ៉ាងណាឲ្យតែនៅក្នុងAmandari នៅឡើយនាងនៅតែមិនទាន់យល់ថាខ្លួនមានសេរីភាពទេ។

ប៉ុន្តែនាយBirdមិនព្រមឲ្យនារីយើងសម្រេចគោលដៅបានងាយស្រួលទេ គេស្ទុះមកស្ទាក់ផ្លូវដោយវិធីនិយាយគួរសមៈ

-អ្នកនាងកេតឪម៉ា ចាំខ្ញុំជូនត្រឡប់ទៅវិញទាន!

ស្រីស្រស់ស្រឡាំងកាំង និងការយកចិត្តយកថ្លើមជ្រុលនេះ។ នាងបដិសេធភ្លាមៈ

-អត់....អត់ទេ...គឺ....គឺ...ខ្ញុំខ្ញុំទៅខ្លួនឯងបានបង!

នាយBirdប្រឹងលំអោនកាយតាមបែបបាវបម្រើស្លូតត្រង់ៈ

-បទបញ្ជាលោកប្រុសរាមទាន! ខ្ញុំមិនចង់អោយមានបញ្ហាដាច់ខាត ពិសេសនៅទីនេះមិនមែនដូចស្រុកខ្មែរទេអ្នកនាង!

ស្រស់ស្រីគ្មានជម្រើសទេ...នាងចាំបាច់ត្រូវធ្វើតាមដែលនាយBirdប្រាប់ព្រោះទោះបីថាប្រកែកក៏នៅតែប៉ុណ្ណឹង។ នាងត្រូវបានបុរសបង្កប់ខ្លួនជូនដំណើរចាកចេញពីAmandariតាមរថយន្តតម្រង់មកកាន់ទីស្នាក់របស់នាង ។

នៅចប់តាមផ្លូវនារីបង្ហាញម៉ូតរក្សាភាពស្ងប់ស្ងាត់មិនចេញស្តីហើយផ្តោតអារម្មណ៍ទៅលើការត្រៀមរៀបចំចេញដំណើរត្រឡប់មកកាន់មាតុប្រទេសវិញជាចម្បងដោយនាងមិនដឹងទេថាការពន្យារពេលឲ្យនាងបន្តនៅឥណ្ឌូណេស៊ី គឺជាផែនការបន្ទាប់របស់មនុស្សមួយក្រុមដែលនាងមិនធ្លាប់នឹកស្មានដល់ថាពួកគេរួមគំនិតគ្នាប្រើប្រាស់នាង។

ក្នុងពេលជាមួយគ្នានោះ នាយBirdដែលជាបក្សពួកបង្កប់ខ្លួនរបស់ Kenតាមដានទឹកមុខធីតាយើងមិនហ៊ានប្រហែសដើម្បីស្វែងយល់ថាតើនាងកំពុងមានអារម្មណ៍យ៉ាងណាចំពោះការងារដែលនាយKenដាក់ឲ្យ និងថាតើនាងមានជំហរយ៉ាងណាចំពោះរាមនរិន្ទ មនុស្សក្នុងគោលដៅរបស់ក្រុមខ្លួន។

នៅពេលជំនិះហើបនឹងចូលមកដល់សណ្ឋាគាររបស់នាងទៅហើយ ស្រាប់តែឪម៉ាឮសួរនាយBirdបន្លឺដោយសព្ទសំឡេងភ្ញាក់ផ្អើលៈ

អីគេហ្នឹង?

ឌីម៉ាចាំបាច់ត្រូវតែងើបមុខសម្លឹងទៅក្រៅឡានតាមប្រយោគភ្លាត់ឡើងរបស់អ្នកបើកបរ។ នៅមិនដល់១០ម៉ែត្រពីទីតាំងរបស់នាង ហេតុការណ៍គួរឲ្យតក់ស្លុតមួយកំពុងកើតឡើង គឺស្រីម្នាក់ប្រកបដោយរូបសម្រស់កំពុងត្រូវបានបុរសបីនាក់ខ្ទប់មាត់អូសឡើងឡាន។ ទោះបីថាសកម្មភាពនោះរហ័សយ៉ាងណា ឌីម៉ានៅតែមើលស្គាល់ថានារីរងគ្រោះដែលគ្មានលទ្ធភាពតបតនោះ គឺលំអងមិត្តរបស់នាងប្រាកដណាស់។ ឌីម៉ាទៅជាស្រឡាំងកាំងទន្ទឹមនឹងពេលនាយBirdនិយាយបន្ថែម៖

ម៉េចគេចាប់ស្រីកណ្ដាលថ្ងៃអញ្ចឹង? ស្រីនោះដូចជាប្រហែលមុខអ្នកនាងឌីម៉ា?

សម្ដីនាយBirdធ្វើឲ្យឌីម៉ាភ្ញាក់ចេញពីភាពភាន់ភាំង នាងដឹងថាមិត្តកំពុងស្ថិតនៅក្នុងគ្រោះថ្នាក់ហើយនាងត្រូវធ្វើអ្វីម្យ៉ាង ប៉ុន្តែនាងមិនដឹងថាត្រូវធ្វើយ៉ាងណាឡើយ។ឌីម៉ាតបជាមួយបុរសអង្គរក្សតាមអារម្មណ៍តក្កមា៖

គេ..គេ...ជាមិត្តខ្ញុំបង! ជួយ...ជួយគេផងទៅបង! ជួយផង!

នាយBirdលួចញញឹមក្នុងចិត្តកាលបើឃើញភាពតក់ស្លុតរបស់នារីបង្ហាញម៉ូតក្បែរខ្លួនកំពុងបញ្ចេញមកត្រូវតាមផែនការ។ គេធ្វើជាបត់ឡានប្រដេញតាមរថយន្តសម្ដែងល្ខោនដែលនៅខាងមុខកិតៗ ហើយក្រុមសម្ដែងល្ខោនកាន់តែបានដៃបង្កើនល្បឿនរត់គេចស្ទើរកក្រើកដែនកោះទេសចរ។

ឌីម៉ាតក់ស្លុតនៅពេលដឹងថានាយBirdគ្មានលទ្ធភាពក្នុងការតាមទាន់រថយន្តដែលមានលំអងទៅជាមួយនោះទេ។ នាងកាន់តែស្ទុះស្ទាអង្គុយលែងជាប់។

-ធ្វើម៉េចទៅបង យើងធ្វើម៉េចទៅ!

នាយBirdស្រាប់តែបន្ថយល្បឿននៅក្រោមក្រសែភ្នែករលើបរលោងរបស់តរុណី។នាងកាន់តែភ័យបារម្ភពោលសួរមិនបង្អង់៖

បង! ហេតុអី?ហេតុអីមិនតាមទៀតទៅបង! គេយកលំអងមិត្តខ្ញុំទៅហើយ! ជួយផងបង!

នាយBirdសម្តែងល្ហៃនចិត្តស្មោះងាកមករកស្រីស្អាតដែលកំពុងអង្គុយក្រោយខ្នង។ គេតបដោយមុខស្លូត៖

អត់បានទេអ្នកនាង! វាដូចជាកំពុងចង់ឲ្យយើងតាមទៅកន្លែងណាមួយ! គ្នាវាច្រើនណាស់!ខ្ញុំខ្លាចទៅតាមវានាំបញ្ហាដល់អ្នកនាងម្នាក់ទៀត!

ឌីម៉ាបើកភ្នែកធំៗពេលឮសម្តីរំលឹកសមហេតុផល ប៉ុន្តែរូបភាពរងគ្រោះរបស់លំអងនៅតែអណ្តែតមកបិទបាំងការគិតវែងឆ្ងាយរបស់នាង។ នាងនៅតែចចេស ៖

តែលំអងកំពុងក្នុងដៃគេ! ធ្វើម៉េចទៅ! យើងមានតែតាមឡាននោះទៅបង បើមិនអញ្ចឹងនឹងមានបញ្ហាហើយ!

នាយBirdពន្យល់វិញ៖

ត្រឡប់ទៅរកលោកប្រុសរាមសិនទៅអ្នកនាង! លោកប្រុសមានស្គាល់គេច្រើននៅទីនេះ! លោកអាចជួយបាន! កុំប្រថុយនាំគ្រោះថ្នាក់ខ្លួន!

នៅពេលតក្កមាអ្វីក៏ដោយសុទ្ធតែជាមធ្យោបាយទាំងអស់លើកលែងតែរាមនរិន្ទចេញ។ ឲ្យតែឮឈ្មោះគេ គឺនាងនឹកឃើញតែរឿងជៀសឆ្ងាយមួយមុខគត់។ នាងគ្រវីក្បាល៖

អត់ទេ! បងឈប់ឡានទៅ ខ្ញុំរកមធ្យោបាយខ្លួនឯង!

ប្រសិនបើនាយBirdពិតជាស្មោះស្ម័គ្រចំពោះរាមនរិន្ទគេពិតជាមិនឲ្យស្រីស្អាតនេះចុះចេញពីឡានបានងាយទេ តែនេះគេក៏មានបំណងចង់ឲ្យនាងទៅជួប Kenតាមផែនការ ម្ល៉ោះហើយគេធ្វើជាបន្ថយល្បឿនល្មមដែលស្រីស្រស់អាចចុះចេញបាន តែមាត់ធ្វើជាពោលឃាត់៖

អ្នកនាងឌីម៉ាគិតឲ្យស្រួលសិន មានតែលោកប្រុសរាមទេដែលអាចជួយបាន!

ឥតគិតច្រើន ស្រីស្រស់លូកដៃចុចទ្វារឡាន រួចហើយឈានជើងចុះទាំងប្រញាប់ប្រញាប់ធ្វើឲ្យនាយBirdបញ្ឈប់រថយន្តទាំងជំហរ។

ភាគទី១៣

ស្រីស្រស់រត់ចេញទាំងមិនបានលាមួយម៉ាត់។ នាយBirdតាមសម្លឹងនារីរូបល្អពីក្រោយ ដែលកំពុងរត់ចេញទៅ។ គេសប្បាយចិត្ត គ្រប់បែបគ្រប់យ៉ាងដំណើរការដោយរលូនហើយលើកទូរស័ព្ទទាក់ទងទៅថៅហ្វាយពិត ធ្វើសេចក្តីរាយការណ៍៖

Ken! ស្រីនោះចុះពីឡានខ្ញុំហើយ អត់ព្រមទៅរកវាមនរិន្ទទេ តែប្រហែលទៅរកបងឯងហើយ! ត្រៀមឲ្យហើយទៅ!

## វគ្គទី៧

## បេសកកម្មជួយមិត្តក្លែងក្លាយ

Kenលូកដៃអង្អែលក្បាលនារីសង្សារដែលអង្គុយយំសស្រាក់នៅចំពោះមុខខ្លួន។ គេដឹងថាត្រីកំពុងស៊ីនុយ ហើយនាងលែងគិតពីរឿងទៅភ្នំពេញវិញដែរ។ គេចាប់ផ្តើមពោលលួងលោម៖

-បាលីអត់ធំប៉ុន្មានទេ! បងឲ្យគេតាមរកពួកម៉ាក់ឪម៉ាភ្លាម!

ពាណិជ្ជករផ្នែកដែកថែបដ៏ល្បីឈ្មោះ ធ្វើជាក្រោកដើរចេញទៅធ្វើការងារជួយដល់នារីម្ចាស់ចិត្តប៉ុន្តែគេដឹងច្បាស់ណាស់ថាមានអ្វីកើតឡើងនាពេលបន្តិចទៀត។ ដូចផែនការដែលបានគ្រោងទុកជាស្រេចសូរស័ព្ទSMSមកកាន់ទូរស័ព្ទនាងបានជួយឲ្យគេត្រូវតែរក្សាវត្តមាននៅក្បែរឪម៉ាដដែល។

នាងក្រមុំស្លូតត្រង់ប្រញាប់ប្រញាល់លើកទូរស័ព្ទមកអានសារដោយទឹកមុខទុក្ខព្រួយ។ នាយKenដឹងថាសារនោះមានន័យយ៉ាងណាហើយ តែគេសម្ងំស្ងៀមរង់ចាំមើលប្រតិកម្មនាង។

ពេលអានសារជាអក្សរចប់ នារីរូបល្អបើកភ្នែកធំៗដោយតក់ស្លុត ចំពោះមុខតួអក្សរ ភាសាអង់គ្លេស២ឃ្លាយ៉ាងខ្លីដែលមានន័យអោយនាងស្វែងរកប្រាក់១០លានRupiahs (មួយម៉ឺនដុល្លារ) ជាថ្នូរនឹងសុវត្ថិភាពមិត្តនារី។ ក្នុងឆាកសម្តែងជាសង្សារយល់ចិត្ត អភិជនKenស្ទុះមកទទួលទូរស័ព្ទពីរដៃស្រីស្រស់ទៅចុចមើល។ គេធ្វើជាប្រែទឹកមុខនៅពេលអាន មកដល់ឃ្លាទី២ដែលសរសេរថា ចាំទទួលសាកសពនាង ទៅបើហ៊ានប្តឹងប៉ូលិស។

គេដៀងភ្នែកមករកឌីម៉ាដែលញ័រដៃជើងនៅចំពោះមុខស្ថានការណ៍ដ៏លំបាក។គេលូកដៃក្រសោបម្រាមនាងទាំង៥ ជាសញ្ញាលួងលោម និងបញ្ជាក់ថាក្នុងស្ថានភាពណាក៏ដោយ គេនៅជាមួយនាងជានិច្ច។

ស្រីស្រស់ស្លូតត្រង់ពិតជាបានធ្លាក់ចូលក្នុងល្បិចដ៏ខ្ពស់របស់មនុស្សស្មោះក្រៅសម្បកតាមផែនការរបស់លំអងមែន។ នាងលើកដៃខ្ទប់មាត់យំគួរឲ្យអាណោចអាធ័ម ព្រោះនាងដឹងថានាងគ្មានសមត្ថភាពណាក្នុងការស្វែងរកប្រាក់ច្រើនម្លឹងដើម្បីជួយលំអងក្នុងគ្រានេះឡើយ។អ្វីដែលនាងគិតមុនគេ គឺកិន្នរីហ្វេស្សិន មានសុទ្ធតែស្រីៗដែលគ្មានកម្លាំង និងគ្មានមធ្យោបាយគ្មានអំណាចអ្វីទាំងអស់។ ពិសេសនេះជាទឹកដីថ្មីមួយដែលនាងមិនស្គាល់វប្បធម៌ និងស្ថានភាព តើនាងអាចធ្វើអ្វីបាន? បើសូម្បីតែប្ដឹងប៉ូលិសក៏មិនបានដែរនោះ?

-កុំយំ! អ្វីក៏អាចដោះស្រាយបានដែរ! តាំងស្មារតីឡើង!

ឌីម៉ាងើបមុខដែលព្រិលទៅដោយជលនេត្រសម្លឹងប្រុសស្នេហ៍នាងគ្រវីក្បាល៖

-ខ្ញុំគ្មានលុយច្រើនយ៉ាងហ្នឹងទេ!

Kenអង្អែលដៃស្រីថ្នមៗបង្ហាញភាពជាបុរសចិត្តស្មោះ។ គេនិយាយតិចៗ៖

-ប្រាក់ប៉ុណ្ណឹងមិនមែនរឿងធំទេ! បងអាចរ៉ាប់រងឲ្យឌីម៉ាបាន! តែបងមានអារម្មណ៍ថារឿងរ៉ាវវាដូចជាមិនធម្មតាអញ្ចឹងសោះចឹងទេ!

នាងក្រមុំសម្លឹងមុខបុរសរូបសង្ហាដែលកំពុងរាយអន្ទាក់ថ្មីបន្ថែមលើអន្ទាក់ចាស់។ដឹងថានាងកំពុងរង់ចាំស្ដាប់ Kenនិយាយថែមទៀតមិនបង្អង់៖

-ពួកអូនសុទ្ធតែជាស្រីៗ តើមានលុយពីណាមក ម៉េចក៏គេចាប់នាងជំរិតប្រាក់?

ឌីម៉ាក្រឡឹងគ្រាប់ភ្នែកសញ្ជឹងគិត។ ពិតមែនហើយ ពួកឧក្រិដ្ឋជនជំរិតមនុស្សមិនសមថាធ្វើការខុសគោលដៅទេ ចុះបើនាងគ្មានលុយមែន តើគេមិនខាតបង់កម្លាំងទទេទៅហើយ?

Kenពោលបន្តដោយសម្លឹងនាងយ៉ាងមុត៖

-រាមនរិន្ទធ្វើទេដឹង?

កេតឌីម៉ាបើកភ្នែកមូលក្លំ។ ប្រមុខកិន្នរីហ្វេស្សិនស្មោះត្រង់រហូតដល់ថ្នាក់មិនយល់ថា ហេតុអ្វីសង្សារសំណព្វបែរជាគិតទៅដល់រឿងបុរសអ្នកនយោបាយ។ នាងបង្ហាញភាពងឿងឆ្ងល់ឲ្យ Kenបកស្រាយបន្ថែម៖

-យប់មិញអូន និងគេយ៉ាងម៉េចខ្លះ? គេធ្វើល្បិចថ្មីចង់ឲ្យអូនទៅរកលុយគេបន្ថែមទេដឹងឌីម៉ា?

កេតឌីម៉ាត្រិះរិះដោយអារម្មណ៍វិលខ្វាល់។ នាងនឹកដល់សម្ដីនាយBirdដែលជម្រុញឲ្យនាងវិលទៅរកជំនួយពីរាមនរិន្ទភ្លាម។ នៅពេលកំពុងប្រដេញឡានពួកចាប់ជំរិតសុខៗ នាយBirdបែរជាឈប់ហើយទូន្មាននាងឲ្យទៅរកថៅហ្វាយគេ ឬមួយសម្ដីរបស់Kenជាការពិត។ សួរខ្លួនឯងបន្ថែម៖

"ឬមួយគេខឹងរឿងយប់មិញយើងដេកលក់! ឬមួយគេខឹងរឿងយើងឡើងយន្តហោះទៅវិញមិនព្រមបន្តនៅទីនេះជាមួយគេ។ ឬមួយគេចង់យកលំអងមកជានុយឲ្យយើងខ្ចីលុយគេមួយជាន់ទៀត?"

នាងងាករកកំលោះជាគូស្នេហ៍ដែលនាងខំជឿជាក់។ យល់ចិត្តនាងKenនិយាយបន្ថែម៖

-នៅ Amandariមានរឿងអីខ្លះ?

តរុណីដែលកំពុងលង់បញ្ឆោតនិយាយមួយប្រាប់សង្សារ៖

-អូនភ័យពេកច្រឡំផឹកកែវទឹករបស់គេ អូនក៏គេងលក់រហូតដល់ពេលនេះ!

Kenធ្វើជាភ័យបារម្ភពីនាង គេសម្លឹងនាងពីលើដល់ក្រោមជាមួយសំនួរបែបទីរទើ៖

-អញ្ចឹង...វា...?

នារីដឹងថាKenបារម្ភខ្លាចរាមនរិន្ទឆ្លៀតឱកាសយកចំណេញលើខ្លួនប្រាណនាង ដែលនាងច្បាស់ណាស់ថាគ្មានរឿងនោះកើតឡើងទេ ដូច្នេះហើយនាងគ្រវីក្បាលតបវិញ៖

-អត់...អត់ទេ...

អភិជនបោកប្រាស់ធ្វើជាសម្ដែងទឹកមុខធូរចិត្ត។ តែបន្ថែមពីនោះគេពោលពន្យល់នាង៖

-បងយល់ហើយ! អាកូនតំណាងរាស្ត្រហ្នឹងអាចខឹងថាអូនមិនបានបម្រើផ្គាប់ផ្គុនវា ពិសេសអូនជិតត្រឡប់ទៅភ្នំពេញវិញ វាក៏បង្កើតរឿងចាប់ជំរិតនេះឡើង ដើម្បីឲ្យអូនត្រឡប់ទៅរកវាវិញ។

កេតឌីម៉ាកាន់តែគិតកាន់តែស្របតាមគំនិតKen។ នាងនឹកដល់ពេលដែលនាងលួចចេញមក គឺរាមនរិន្ទមិនទាន់ពេលឲ្យនាងឃ្លាតពីគេនៅឡើយ ហើយថែមទាំងឃាត់នាងអោយពន្យារពេលនៅបាលីបន្តផង ពិសេសពេលចុះមកដល់ជាន់ក្រោមក៏មាននាយ Birdចាំជូនជាស្រេច។ ពេលជិះជាមួយនាយអង្គរក្សនោះ ស្រាប់តែគាប់ជួនទៅដល់កន្លែងដែលអាចមើលឃើញលំអងត្រូវគេចាប់។ នាងស្រាប់តែចាប់អារម្មណ៍ថា

អ្វីៗដូចជាត្រូវបានគេរៀបចំរួចជាស្រេចមែន។

នាងជ្រប់មុខស្រក់ទឹកភ្នែក។ នាយKenដឹងថានាងលង់ជឿពាក្យបោកប្រាស់របស់ខ្លួនឥតសង្ស័យគេបានចិត្តណាស់ ក៏បន្តឆាកល្ខោនដោយអង្អែលក្បាលស្រស់ស្រីថ្នមៗ។ នារីពោលរអាក់រអួល៖

បងKen! លំអងជាមនុស្សល្អ នាងមិនដឹងអីទេ! ខ្ញុំត្រូវទៅរកមនុស្សអាក្រក់នោះដើម្បីឲ្យគេដោះលែងលំអងមកវិញ!

សង្ស្រារហេងស៊យរបស់នារីរូបល្អនិយាយកាត់ដើម្បីបញ្ចប់ភាពរន្ធត់របស់នាង៖

-កុំគិតអីតក់ក្រហល់ពេកឌីម៉ា! បងគ្មានបញ្ហាទេសម្រាប់ការជួយអូន?

នារីងក់ក្បាលផ្ងក់ៗ៖

-ខ្ញុំក៏មិនចង់ឲ្យបងKenឲ្យលុយទៅមនុស្សអាក្រក់ហ្នឹងដែរ ខ្ញុំនឹងទៅជួបគេ ចង់ដឹងថាគេចង់យ៉ាងម៉េចទៀត? ជាកូនប្រុសដើមទ្រូង៥ហត្ថ មានពូជត្រកូលត្រឹមត្រូវមកធ្វើរឿងដូចជនអន្ធពាល!

Kenសប្បាយចិត្តណាស់នៅពេលស្រីស្អាតរូបនេះទទួលស្គាល់ថារាមនរិន្ទជាមនុស្សអាក្រក់។ ឲ្យឌីម៉ាព្រមបន្តនៅជិតរាមនរិន្ទ គឺជាគោលដៅដ៏ធំរបស់គេ ព្រោះរហូតដល់ពេលនេះគេនៅតែមិនជឿថារាមនរិន្ទមកកាន់កោះបាលី គ្រាន់តែដើម្បីទស្សនាការបង្ហាញម៉ូតអាស៊ីនោះទេ។ តែក្នុងស្រោមជាសុភាពបុរសថ្លៃថ្នូរ គេត្រូវបង្ខំចិត្តនិយាយឃាត់នាង៖

-អាម្នាក់នោះមានល្បិចច្រើនម្លឹងៗ អូនឈប់ទៅក្បែរវាទៅ បងលែងយកសង្សារដ៏ល្អរបស់បងទៅប្រថុយទៀតហើយ!

មាណវីមិនដឹងពុតសង្សារទេ នាងវាចាដោយសេចក្តីទៀងត្រង់៖

-តែខ្ញុំបារម្ភពីលំអងណាបង?

Kenនិយាយវិញភ្លាម៖

-បងចេះដោះស្រាយជាមួយមនុស្សអាក្រក់នោះហើយ! ទុកឲ្យបងចេញមុខ! យើងធ្វើតែអំពើល្អមិនត្រូវខ្លាចមនុស្សអាក្រក់ទេ! គិតទៅមនុស្សអាក្រក់ទៅដល់ណានៅតែអាក្រក់មែន! តែស្រុកទេសគេមានច្បាប់របស់គេ វាមិនអាចធ្វើអីតាមចិត្តនឹកឃើញទេឪម៉ា!

កាន់តែស្តាប់សង្សារនិយាយ ស្រស់ស្រីកាន់តែបារម្ភ។ នាងវាចាទៅកាន់គេ៖

-បងKen! រាមនរិន្ទមិនមែនធម្មតាដូចបងគិតទេ! គេមានបណ្តាញនៅទីនេះច្រើនណាស់ គេគេអាចនាំទុក្ខដល់បងKenបាន!

ពាក្យថារាមនរិន្ទមានបណ្តាញនៅទីនេះច្រើន ដែលទើបរបូតចេញពីមាត់តរុណីយើងបានទាញKenឲ្យចាប់អារម្មណ៍ថានាងប្រាកដជាដឹងរឿងរ៉ាវសំខាន់ខ្លះពាក់ព័ន្ធនឹងគូប្រជែងរបស់ខ្លួនជាមិនខាន។ ហើយនេះក៏ជាអ្វីដែលខ្លួនកំពុងឮដែរ។ សម្តីរបស់ឪម៉ាអាចនឹងជួយឲ្យខ្លួនស្រាយនូវចម្ងល់ថា តើរាមនរិន្ទនាំគ្នាមកបាលីច្រើនដល់ម្លឹងដើម្បីអ្វី?

បុរសអភិជនងាកសួរនារីក្បែរកាយភ្លាម៖

-ម៉េចក៏អូនដឹងរឿងបណ្តាញរបស់អាម្នាក់នោះនៅបាលីនេះ?

ស្រីស្អាតនិយាយតបតាមភាពទៀងត្រង់៖

-ដូច...ដូច...ដូចជាមិនមែននៅបាលីនេះតែឯងទេ គឺ...គឺកន្លែងផ្សេងទៀតនៅក្នុងប្រទេសឥណ្ឌូណេស៊ីនេះដែរ..

ចម្លើយនេះទាក់ចិត្តKenជាខ្លាំង។ គេសម្លឹងមកស្រស់ស្រីយ៉ាងមុតហាក់ចង់ប្រមូលយកឲ្យអស់នូវការចងចាំ ទាំងអស់របស់នាងទាក់ទងនឹងរាមនរិន្ទ។ គេបន្លឺជាប្រញាប់៖

-កន្លែងណា? ហើយម៉េចបានអូនដឹង? ឬមួយរាមនរិន្ទនិយាយប្រាប់?

កេតឌីម៉ាឆ្លើយតបដោយមិនខ្វល់ចំពោះភាពប្រែប្រួលរបស់សង្សារខ្លួន៖

-យប់មិញពេលអូនត្រូវថ្នាំគេងលក់ អូននៅតែស្តាប់ឮល្វើយៗ! រាមនរិន្ទនិយាយគ្នាជាមួយអ្នកផ្សេងទៀតដល់យប់ជ្រៅ! អូនស្រពិចស្រពិល ដូចជាក្នុងយល់សប្តិ តែអូនឮគេនិយាយពីកន្លែងណាទេ ត្រូវជិះយន្តហោះវាង មួយថ្ងៃមួយយប់!

អភិជនKenមានអារម្មណ៍ដូចមនុស្សស្រេកទឹកដើរជំពប់នឹងស្រះថ្លាឆ្វង់។ គេយល់ហើយពីអ្វីដែលនាងកំពុងនិយាយ។ គឺធម្មតាមនុស្សរងឥទ្ធិពលនៃថ្នាំសណ្តំអាចដេកស្តូកស្តឹងមិនអាចបើកភ្នែក មិនកម្រើកដៃជើង ឬមិនដឹងពីអ្វីដែលកើតឡើងជុំវិញខ្លួន ប៉ុន្តែត្រចៀកជារឿយៗគឺនៅអាចចាប់បានសូរសំឡេងទាំងឡាយមិនច្រើនក៏តិចដែរ។ចំណែកសំឡេងទាំងនោះអាចរក្សាទុកក្នុងអង្គចងចាំបានកម្រិតណា អាស្រ័យសមត្ថភាពរបស់មនុស្សនោះផ្ទាល់។

ពាណិជ្ជករមានល្បិចលួចញញឹមក្នុងចិត្តត្បិតថាសូម្បីទេវតាក៏ជួយសម្រេចគោលបំណងឲ្យគេដែរ។ប្រសិនបើថ្នាំមួយកូនដបនោះត្រូវបានរាមនរិន្ទផឹកវិញ គេមុខតែមិនបានដំណឹងអ្វីទាំងអស់ តែនេះគឺផ្ទុយគ្នា។ រាមនរិន្ទ និងបក្សពួកបានមើលរំលងកេតឌីម៉ា ដោយសារឃើញថានាងសន្លប់ស្តូកស្តឹង ទៅហើយ។ ចន្លោះប្រហោងនេះអាចធ្វើឲ្យគេភ្លាត់ចេញនូវផែនការសម្ងាត់ទាំងឡាយនៅបាលី។

ភាគទី១៤

ចាំអីទៀត? នាយKenប្រញាប់ពោលពន្យុះតរុណីភ្លាម៖

-ល្អណាស់! ឆាប់...ឆាប់នឹកឡើងវិញមើល៍ឌីម៉ា! អូននៅឮអីទៀត? គិតមើល៍ឌីម៉ា! ពួកវានិយាយគ្នាពីរឿងអ្វីខ្លះកាលពីយប់មិញ?

ឌីម៉ាហាក់ភ្ញាក់ផ្អើលចំពោះអាកប្បកិរិយាសង្សារដែលប្រែទៅជាអន្ទះសាជាងមុន។នាងនៅទ្រឹងបើកភ្នែកមូលក្លំសម្លឹងនាយ។ហាក់ដឹងខ្លួនវិញ នាយKenខំសង្រួមអារម្មណ៍មកវិញកុំឲ្យនាងចាប់អារម្មណ៍ជាងនេះដោយរកវិធីពោលបង្វែងដាន៖

-ព្រោះ...ព្រោះបងយល់ថា អ្វីដែលពួកហ្នឹងនិយាយគ្នាអាចទាក់ទងជាមួយគម្រោងចាប់ជំរិតលំអង! បើសិនអូនអាចចាំបាន អ្វីទាំងអស់ហ្នឹង ត្រូវប្រាប់បងភ្លាម!

សុវត្ថិភាពនារីជាមិត្តគឺជាគន្លឹះធ្វើឲ្យកេតឌីម៉ាត្រូវតែព្យាយាមជាងមុនក្នុងការរំលឹកមកវិញនូវសូរស័ព្ទដែលនាងបានឮកាលពីយប់មិញ។ នាងបិទភ្នែកប្រមូលអារម្មណ៍ តាំងស្មារតីរំលឹកមកវិញក្រោមក្រសែភ្នែករង់ចាំដោយអន្ទះសារបស់សុភាពបុរសក្លែងក្លាយ។ពេលនាងបើកភ្នែកមកវិញKenក៏សម្លឹងនាងដោយអន្ទះសា។ ធីតារូបល្អសម្លឹងនាយដោយក្រសែភ្នែកស្ទាក់ស្ទើរ តែនាងត្រូវបានបុរសពោរពេញដោយបទពិសោធន៍និយាយលើកទឹកចិត្តភ្លាមៈ

-និយាយមក! អ្វីក៏ដោយឌីម៉ា! អ្វីក៏បាន! កុំគិតថាសំខាន់ មិនសំខាន់! អូនឮអី! ចាំបានអីនិយាយឲ្យអស់មក!

នាងក្តាប់ដៃ ជ្រួញថ្ងាសយ៉ាងតឹងតែងព្រោះប្រឹងប្រមូលការចងចាំទាំងអស់មកដាក់បញ្ចូលគ្នាឱ្យទៅជាចម្លើយល្អអាចស្តាប់បានមួយ។ ទីបំផុតស្រស់ស្រីហើបមាត់និយាយតិចៗៈ

-គេនិយាយពីកន្លែងមួយឈ្មោះ......ឈ្មោះ.....

នៅពេលនាងជ្រួញចិញ្ចើមតឹងតែងកាន់តែខ្លាំង នាយKenខំទប់កំសួលចិត្តអន្ទះសា គេពោលលួងថ្នមៗៈ

-គិតតាមសម្រួលទៅឌីម៉ា! កន្លែងនោះឈ្មោះអី?

-ឈ្មោះ...ឈ្មោះ...ដូចជាមានអក្សរ″រ″ នៅខាងចុង...″រ៉ា″ ឬមួយក៏អ្វីផ្សេងប្រហែលៗហ្នឹងណ៎ាបងKen

តែគេត្រូវជិះយន្តហោះយូរណាស់ដល់ទៅមួយថ្ងៃមួយយប់ ត្រង់នេះអូនចាំច្បាស់ជាងគេ!

នាយKenបើកភ្នែកធំៗ។ គេមិនមាត់មួយម៉ាត់តែគេកំពុងសញ្ជឹងគិត។

‶ប្រទេសឥណ្ឌូណេស៊ីធំយ៉ាងនេះ ជិះយន្តហោះកាត់សមុទ្រទៅកាន់បណ្តាកោះនានាចំណាយពេលវែងបន្តិចក៏គ្មានអីចម្លែកដែរ ប៉ុន្តែតម្រុយប៉ុណ្ណឹងតើអាចឲ្យខ្លួនរកឈ្មោះកន្លែងនោះឃើញដោយវិធីណាទៅ? ″គេនិយាយមួយៗទៅកាន់នារីដែលនៅចំពោះមុខៈ

-ហ្សាកាតា?

នាងគ្រវីក្បាល។

-បាន់ដាអរចេ?

នាងកាន់តែគ្រវីក្បាល។

-កោះចារ៉ា?

នាងនៅតែគ្រវីក្បាល។ Kenដកដង្ហើមយូរ។ គេដឹងថាភាសាបាហាសារបស់ជនជាតិឥណ្ឌូណេស៊ីមានផ្ទុកនូវព្យញ្ជនៈ "រ" បង្កប់ជាមួយសឹងថាគ្រប់ម៉ាត់ ចង់ស្វែងរកមួយក្នុងចំណោមនោះដូចជារាវម្ជុលក្នុងបាតសមុទ្រអញ្ចឹងដែរ។ អញ្ចឹងហើយគេប្រញាប់បង្វែរទៅរកចំណុចជំនួយផ្សេងទៀត។

-បានហើយ! អូនអត់ចាំក៏មិនអីដែរ! តែពួកគេទៅទីនោះធ្វើអី?

នារីគ្រវីក្បាលដោយទឹកមុខស្រងូត ជាសញ្ញាថានាងគ្មានយោបល់ទេព្រោះអត់ដឹង។ស្រាប់តែរំពេចនោះ Kenហាក់ទើបតែនឹកឃើញ។ គេងាកមកសួរនាងបន្ថែមភ្លាម៖

-ចុះមុននេះក្រែងអូនថាពួកវាមានបណ្ដាញនៅទីនេះច្រើនអ្វី? បណ្ដាញវាជាអ្នកណា?ឬមួយកន្លែងនោះមានពីណាម្នាក់ដែលពួកវាត្រូវទៅជួប? ឬមួយគេមករកពួកវា? អូននឹកឃើញទេ! ឆាប់រកនឹកទៅ!

ឱម៉ាបើកភ្នែកមូលក្លំ នាងនិយាយតបភ្លាម៖

-គឺរាមនរិន្ទត្រូវទៅទីនោះបងKen! ដូចជាខានស្អែក....ចេញ...ចេញដំណើរ....

"កន្លែងណាទៅ? ទៅរកអ្នកណាទៅ? ហេតុអីបានជាសំខាន់ដល់ថ្នាក់រាមនរិន្ទត្រូវដេកផ្លូវហើយទើបចេញដំណើរ? គេមិនត្រឡប់ទៅភ្នំពេញវិញទេ? "Kenសួរខ្លួនឯង។

គេមិនទាន់រកគិតអ្វីឃើញបន្ថែមផង ស្រាប់តែឮនារីជាគូស្នេហ៍និយាយដោយភ្ញាក់ផ្អើល៖

-មែនហើយបងKen! ខ្ញុំនឹកឃើញពីពាក្យថា កុលសម្ព័ន្ធ គឺមានពាក្យមេកុលសម្ព័ន្ធណាបងKen!

Kenបើកភ្នែកដោយអំណរ។ មានតម្រុយហើយ! កុលសម្ព័ន្ធនៅសេសសល់មិនច្រើនទេ ដូច្នេះវាមិនពិបាករកដូចកាលពីគិតអម្បាញ់មិញដែរ។ តែអ្វីដែលកាន់ប្រាកដទៀតនោះ គឺថាតំបន់នោះប្រាកដជានៅឆ្ងាយពីទីក្រុងធំច្បាស់ណាស់ ពិសេសគឺនៅតំបន់ជាប់ព្រៃ ឬជួរភ្នំតែម្ដង។

គេបង្ខើបមាត់បន្ទរពីនាង៖

-ចុះគេទៅជួបពួកកុលសម្ព័ន្ធធ្វើអីហ្ន៎?

ឪម៉ានិយាយរវើរវាយតាមការចងចាំមកវិញម្តងបន្តិចៗ៖

-ដូចជាទៅរកវត្ថុម្យ៉ាងឈ្មោះ...ឈ្មោះ...ដូចក្នុងរឿងល្ខោនបុរាណ...ឈ្មោះធិប...ធិប

Kenមិនអាចរង់ចាំតទៅទៀតបានឡើយនៅពេលនាងបង្អើបដល់ចំណុចនេះម្ល៉ោះហើយគេភ្លាត់មាត់៖

-ឥន្ទប្បដិមា នរាធិបតិន្ទ?

ដល់ពេលឪម៉ា ត្រូវភ្ញាក់ផ្អើលម្តង ព្រោះKenនិយាយមកត្រូវចំពេក។ សម្តីបង្ហើយរបស់គេ ធ្វើឲ្យ នាងរំលឹកមកវិញស្ទើរ៦០ភាគរយនៃអ្វីដែលរាមនរិន្ទបានសន្ទនាជាមួយនាយរឿន។

-ត្រូវហើយ! គឺរបស់នោះហ្នឹងមែន! ម៉េចបានបងKenដឹង?

អភិជនសម្បូរកល ច្រត់ដៃក្រោកដោយទឹកមុខរីករាយ គេមិនឆ្លើយនឹងសំនួរនាងតែគេគិតម្នាក់ឯងស្ងាត់ៗ៖

"ស្រីល្ងង់! នោះជារបស់ដែលយើងតាមរកសឹងកន្លះជីវិតមកហើយ! រឿងអីថាយើងមិនដឹង! សំខាន់គឺរាមនរិន្ទពិតជាបានជួយយើងឲ្យរកឃើញរបស់ទិព្វនេះមែន! ល្បិចខ្ចីដៃវាប្រើនេះមិនអត់អំពើទេ!"

គេដាក់អារម្មណ៍មកវិញនៅពេលឮស្រីស្រស់សួរបន្ត៖

-បងKenកំពុងគិតអី?

ឃើញនារីក្រោកឃឹតៗពីកៅអី គេលូកដៃមកក្រសោបម្រាមទាំង១០របស់នាង។ គេដឹងថាការប្រើស្រីម្នាក់នេះ គឺជាការជ្រើសរើសកូនអុកមួយដែលនៅសល់ក្រឡាដើរច្រើនទៀតក្នុងសមរភូមិទល់ជាមួយរាមនរិន្ទ ម្ល៉ោះហើយបន្តមកទៀត កេតឪម៉ាគួរតែនៅកាន់តែកៀកជាមួយកូនប្រុសអ្នកតំណាងរាស្ត្រនោះ។

គេនិយាយបញ្ឆោតនាង៖

-ឪម៉ា!បងសង្ស័យថា គេបញ្ជូនលំអងទៅកន្លែងហ្នឹង!

ឪម៉ាបើកភ្នែកធំៗដោយភិតភ័យ៖

-ហេតុអី? ហេតុអីគេធ្វើអញ្ចឹង?

Kenនិយាយភ្លាម៖

-អូនគិតមើលទៅ! សុខៗយប់មិញពួកវានាំគ្នានិយាយពីរឿងហ្នឹង តែព្រឹកឡើងស្រាប់តែមានរឿងចាប់លំអង! បងខ្លាចវាមានការទាក់ទងគ្នា!

ឪម៉ាប្រកែកភ្លាម៖

-តែលំអងមិនដែលធ្វើអីពួកគេទេ គេធ្វើបាបលំអងធ្វើអី? ខ្ញុំអត់យល់ទេបងKen?

បានដូចចិត្តKenបន្លឺពន្យល់ភ្លាម៖

-បង និងអូនសុទ្ធតែអត់យល់ មានតែមនុស្សអាក្រក់អស់ហ្នឹងទេដែលគេយល់ច្បាស់ថាកំពុងលេងល្បិចអី! អញ្ចឹងបើចង់ដឹងច្បាស់ និងអាចជួយលំអងកុំឲ្យមានបញ្ហា យើង...

ឪម៉ាសួរដោយតក់ក្រហល់៖

-ធ្វើយ៉ាងម៉េចទៅបងKen?

-ទៅរកគេ ហើយធ្វើពើជាមិនដឹងរឿងអីទាំងអស់! នៅកាន់តែជិត កាន់តែល្អ! យើងនឹងអាចដឹងពីបំណងគេច្រើនជាងហ្នឹង!

-ចុះការជំរិតលុយនេះ?(នារីសួរដោយទឹកមុខព្រួយបារម្ភ)

Kenពន្យល់នាង៖

-សរសេរទៅគេវិញទៅ ថាលុយយើងឲ្យតែមនុស្សត្រូវបានសុខ! ហើយអូនធ្វើជាទៅជួបរាមនរិទ្ធឲ្យវាជួយអូនក្នុងរឿងនេះ! ចាំណាំកេតឪម៉ា បើវាបបួលអូនឲ្យទៅកន្លែងណាមួយជាមួយវា ជាពិសេសកន្លែងកុលសម្ព័ន្ធនោះ អូនត្រូវទៅតាមវាជានិច្ច កុំប្រកែកណ៎ា!

នារីកាន់តែបង្ហាញភាពភ័យខ្លាចលើផ្ទៃមុខ។ នាងសួរបញ្ជាក់៖

-បងKenឲ្យអូនតាមចិត្តមនុស្សចិត្តពាលហ្នឹងទាំងអស់អញ្ចឹងអ្វី?

-ត្រូវឪម៉ា! ព្រោះគោលដៅរបស់វាប្រហែលជាអូន! បានជាវាចាប់លំអង! បើអូនមិនតាមបំណងវា លំអងម៉េចបានមកវិញ? ចំណែកសុវត្ថិភាពអូន បងចេះគិតគូរហើយ! ត្រូវចាំថាអូនទៅដល់ទីណា បងក៏នៅទីនោះដែរ! ទាក់ទងគ្នាជាប់ជានិច្ចណាឪម៉ា! កុំភ្លេចមនុស្សមួយចំនួនដែលបង្ហាញខ្លួននៅជិតអូន អាចជាមនុស្សរបស់បង! អូនត្រូវក្លាហាន! ភារកិច្ចដែលអូនត្រូវធ្វើនោះ គឺត្រូវដឹងទាំងអស់ថាក្រុមនោះកំពុងធ្វើអ្វី!

Kenចាកចេញពីបន្ទប់នាងបន្សល់ទុកឲ្យនារីស្លូតត្រង់តែមិនសូវមានប្រាជ្ញានូវសម្ពាធដ៏ធំ។ នាងរៀបចំខ្លួនប្រាណសាជាថ្មីដើម្បីត្រឡប់ទៅបង្ហាញខ្លួនចំពោះរាមនរិន្ទតាមគម្រោងការថ្មីទាំងចិត្តភិតភ័យមិនស្ងប់។

កំពុងអង្គុយសិតសក់នៅមុខទូសម្អាងដោយស្លេកស្លាំងសំឡេងទូរស័ព្ទនាងលាន់ឡើង។ នាងលើកមកទទួលដោយប្រញិបប្រញាប់។ មិនទាន់បានហាមាត់មួយម៉ាត់ផងសម្លេងពីចុងម្ខាងលាន់មកស្រួយ ស្រេះ៖

-បងឪម៉ា! ជិតដល់ម៉ោងហើយ! ឡានTaxiកំពុងចាំ! ចុះមកឲ្យលឿន! លំអងក៏មិនទាន់ចុះមកដែរ!ឆាប់ឡើងប្រយ័ត្នខកយន្តហោះ!

ឪម៉ាដកដង្ហើមធំ។ នាងត្រូវរកវិធីពន្យល់ពួកគេថានាងនិងលំអងមានការងារត្រូវបន្តធ្វើនៅបាលីជាការងារទាក់ទងដល់ផលប្រយោជន៍របស់កិន្នរីហ្វេស្សិនហើយឲ្យពួកគេត្រឡប់ទៅមាតុប្រទេសមុន។

ព្រះរាជាណាចក្រដែលនាងស្រលាញ់ស្មើជីវិត នៅតែឆ្ងាយសន្លឹមពីមាណវីយើងនៅឡើយ។ នាងបញ្ចប់ការតុបតែងខ្លួន ហើយប្រញាប់បន្តសកម្មភាពថ្មីតាមគម្រោងផែនការដែលKenបានបង្រៀនមុនពេលគេចាកចេញពីនាងទៅ។